ព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា

ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

# ឯកសារណែនាំគ្រូបង្រៀន

# ស្តីពី

# វិធីសាស្រ្តបង្រៀនដោយបញ្ជ្រាបខ្លឹមសារបន្ថែមពីឯកសារយោង

# សម្រាប់មុខវិជ្ជា

# គណិតវិទ្យា និងវិទ្យាសាស្រ្ត ពីថ្នាក់ទី៧ ដល់ ទី៩

# គីមីវិទ្យា

(សេចក្តីព្រាង)

ឧបត្ថម្ភដោយៈ

គម្រោងអភិវឌ្ឍវិស័យអប់រំទី៣

ESDP3

បោះពុម្ពព្រាង (ខែ តុលា ឆ្នាំ ២០១៦)

**គណៈកម្មការនិពន្ធ**

| | | | |
|---|---|---|---|
| **គណិតវិទ្យា** | លោក ហែម សុខល័ក្ខ | លោក ប៊ូ សន | លោក ព្រំ ងួន |
| | លោក វៀច កា | លោក ឌុច មករា | លោក ឈឹន សម្បត្តិ |
| | លោក ឈាន ហាង | លោក ស្រី វុធ | លោក ឯក លីម |
| | លោក ប៊ុន ណារ៉ាន់ | លោក ស៊ុម សំអឿន | លោក ខាត់ ឃាង |
| | លោក ហួន ណូ | លោក តាយ ណារិន | លោក ហេង សីហា |
| | លោកស្រី សេង សុវ៉ាត | លោក លី ពិសិដ្ឋ | លោក លី សាម៉ាល់ |
| | លោក ម៉េង រិន | លោក ប៉ោក ស្រេន | លោក នីម លេងហេង |
| | លោកស្រី ជា សុគន្ធារី | លោក ជិន ភិរម្យ | លោកស្រី ជិន បុប្ផា |
| | លោក និក ហែន្ទ | | |
| **រូបវិទ្យា** | លោក ធាន វាសនា | លោក ម៉ែន វណ្ណារី | លោកស្រី ម៉េះ ចាន់ថេត |
| | លោក ដាញ់ សុភី | លោក ធី សាវរិន | លោក និក ហែន្ទ |
| **គីមីវិទ្យា** | លោក បណ្ឌិត សិត សេង | លោក គុង រ៉ូហ្សេត | លោកស្រី ប៊ុន ជានស៊ីផល |
| | លោក អ៊ឹង សុខា | លោក ស៊ិន វ៉ាត | លោក និក ហែន្ទ |
| **ជីវវិទ្យា** | លោកស្រី ហួ ឃីម | លោក សុខ សារឿន | លោកស្រី ហ៊ូ ច័ន្ទសារ៉ា |
| | លោកស្រី អ៊ាង សេងលីម | លោកស្រី សៀន ស្រីដេត | លោក និក ហែន្ទ |
| **ផែនដីវិទ្យា** | លោក សុក វុទ្ធី | លោក ប៉េង ប៊ុនថន | លោកស្រី ប៉េង ទិត្យសុទ្ធី |
| | លោកស្រី គឹម បូរីផល | លោក អឿ សុខម៉េង | លោក និក ហែន្ទ |
| **អ្នកវាយអត្ថបទ** | លោក ងិន វិត | លោក ជាប សារិន | លោក ទេព្វ ផល្លា |
| | លោក ជួន ចាន់ពិសិដ្ឋ | លោក លី ណារិទ្ធ | លោក និក ហែន្ទ |
| | លោក សីហា សុង | | |

**វិចិត្រករ**
**រៀបរៀង**
**រចនាទំព័រ**
**គណៈកម្មការពិនិត្យ**

# អារម្ភកថា

ដើម្បីកសាងធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់អាទិភាពខ្ពស់ដល់ការកែលម្អគុណភាពអប់រំលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ។ គម្រោងអភិវឌ្ឍវិស័យអប់រំទី៣ (ESDP3) ជាគម្រោងមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ESDP3-ADB Loan No. 2889-CAM(SF) ក្នុងគោលបំណងកាត់បន្ថយអត្រាបោះបង់ការសិក្សានៅអនុវិទ្យាល័យ។ វត្ថុបំណងគម្រោងអភិវឌ្ឍវិស័យអប់រំទី៣មាន៖

១. ការកែលម្អការចូលរួមអប់រំកម្រិតមូលដ្ឋាន

២. ការកែលម្អគុណភាពអប់រំកម្រិតមូលដ្ឋាន

៣. ការកែលម្អគុណភាពនៃការគ្រប់គ្រងទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន

នៅក្នុងលទ្ធផលទី២ មានសមាសភាគ ២.៣ និង ២.៤ មាន៖

២.៣. ការកែលម្អគុណភាពអប់រំកម្រិតមូលដ្ឋានផ្នែកគណិតវិទ្យា

២.៤. ការកែលម្អគុណភាពអប់រំកម្រិតមូលដ្ឋានផ្នែកវិទ្យាសាស្ត្រ

"ឯកសារណែនាំគ្រូបង្រៀន ស្តីពីវិធីសាស្ត្របង្រៀនដោយបញ្ជ្រាបខ្លឹមសារបន្ថែមពីឯកសារយោង" ថ្មីៗនេះ គណៈកម្មការនិពន្ធបានជ្រើសរើសខ្លឹមសារយ៉ាងសម្រិតសម្រាំងប្រកបដោយអត្ថន័យសំខាន់ៗ ដែលស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ចំណេះដឹង និងសមត្ថភាពផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ ជាបំណិនជីវិតដែលយើងត្រូវការជារៀងរាល់ថ្ងៃ។ ឧទាហរណ៍ពេលយើងធ្វើស្រែ ៖ អ្នកធ្វើស្រែត្រូវការយល់អំពីខ្នាតរង្វាស់រង្វាល់ និងរបៀបរៀបចំថវិកា ដើម្បីមានជោគជ័យ ... ត្រូវការចំណេះដឹងលើមុខវិជ្ជាទាំង៤ក្នុងវិទ្យាសាស្ត្រដូចជា៖ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ។

សិស្សដែលមានសមត្ថភាពខ្ពស់ខាងផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ នឹងបន្តការរៀនសូត្របន្ថែមទៀត ។ ពួកគេនឹងក្លាយជាធនធានមនុស្សដ៏សំខាន់នៅក្នុងសង្គមខ្មែរយើង ។

ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយអង្គការដៃគូជាច្រើនកន្លងមកហើយ ។ ឯកសារណែនាំគ្រូបង្រៀននេះមានគោលបំណងជួយគ្រូក្នុងការបញ្ជ្រាបខ្លឹមសារពីប្រភពផ្សេងៗ និងឯកសារយោងដទៃទៀត ដើម្បីកែលម្អគុណភាពនៃការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។

គ្រូល្អគឺជាគ្រូដែលមានសមត្ថភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់ខ្លួន ។ គ្រូត្រូវប៉ិនប្រសព្វក្នុងការស្រាវជ្រាវឯកសារពីប្រភពផ្សេងៗ ឬការស្រាវជ្រាវលើប្រព័ន្ធInternet នៅថ្ងៃអនាគត។

គណៈកម្មការនិពន្ធ បង្កើតឯកសារណែនាំគ្រូនេះឡើង មានគោលបំណងចូលរួមលើកកម្ពស់គុណភាពអប់រំដោយធ្វើយ៉ាងណាឱ្យគ្រូយល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារថ្មីៗពីឯកសារយោងនានា ទៅក្នុងកិច្ចតែងការបង្រៀន និងម៉ោងសិក្សារបស់ពួកគាត់ ។ គណៈកម្មការនិពន្ធមានជំនឿយ៉ាងមុតមាំថា ឯកសារណែនាំគ្រូបង្រៀន ស្តីពីវិធីសាស្ត្របង្រៀនដោយបញ្ជ្រាបខ្លឹមសារបន្ថែមពីឯកសារយោង ដែលទើបបង្កើតថ្មីនេះ អាចបម្រើផលប្រយោជន៍ដល់អ្នកសិក្សា និងជាទីប្រឹក្សាដ៏ល្អសម្រាប់ជាជំនួយដល់ការអនុវត្តជាក់ស្តែងរបស់គ្រូបង្រៀន និងសិស្សជាមិនខាន ។

គណៈកម្មការនិពន្ធ

# មាតិកា


| | ទំព័រ |
|---|---|
| សេចក្តីណែនាំ.................................................................................................................................. | 6 |
| របៀបបញ្ច្រាបខ្លឹមសារថ្មីៗ.............................................................................................................. | 8 |
| ការណែនាំជាទូទៅសម្រាប់បង្រៀនវិទ្យាសាស្ត្រ................................................................................ | 10 |
| វិធីសាស្ត្របង្រៀន.......................................................................................................................... | 11 |
| ១. ការបង្រៀន និងរៀនតាមបែបរិះរក (IBL)...................................................................................... | 11 |
| ២. រៀនដោយការចូលរួម...................................................................................................................... | 13 |
| ៣. ការប្រើប្រាស់សំណួរបើក............................................................................................................... | 15 |
| ៤. វិធីជ្រើសរើសសិស្សដោយភាពយុត្តិធម៌.......................................................................................... | 15 |
| ៥. សកម្មភាពពិភាក្សា........................................................................................................................ | 16 |
| ៦. ការប្រើប្រាស់ក្តារឆ្នួន...................................................................................................................... | 16 |
| ៧. ការយល់ពីការគិតរបស់សិស្ស.......................................................................................................... | 17 |
| ៨. ការប្រៀបប្រដូច និងគំរូតាង............................................................................................................ | 20 |
| ៩.គ្រូសាកល្បង ហើយព្យាយាមរហូតទទួលបានជោគជ័យ.................................................................. | 21 |
| តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៧.................................................................................. | 22 |
| តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៨.................................................................................. | 23 |
| តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៩.................................................................................. | 24 |
| ផែនការបង្រៀន និងកិច្ចតែងការបង្រៀនគំរូ....................................................................................... | 25 |
| ១. C722 កត្តានៃបំលែងរូបធាតុ (ម៉ោងទី១) ....................................................................................... | 25 |
| ២. C732 កង្វក់ខ្យល់ (ម៉ោងទី១) .......................................................................................................... | 33 |
| ៣. C812 និមិត្តសញ្ញា រូបមន្តគីមី និងប្រតិកម្មគីមី (ម៉ោងទី១) .............................................................. | 39 |
| ៤. C822 វិធីញែកល្បាយ (ម៉ោងទី១) ..................................................................................................... | 49 |
| ៥. C921 កាបូន (ម៉ោងទី១) .................................................................................................................. | 59 |
| ៦. C932 អាំស៊ីត (ម៉ោងទី១) ................................................................................................................ | 67 |
| ឯកសារយោង.................................................................................................................................... | 75 |

# សេចក្ដីណែនាំ

ឯកសារណែនាំគ្រូនេះមានគោលបំណងជួយគ្រូបង្រៀនឱ្យអនុវត្តសកម្មភាពក្នុងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ។

ចំណេះដឹង និងសមត្ថភាពលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រគឺជាបំណិនជីវិតដែលយើងត្រូវការជារៀងរាល់ថ្ងៃ ។

ដូចជា អ្នកធ្វើស្រែត្រូវតែយល់អំពីរង្វាស់រង្វាល់ និងរបៀបរៀបចំថវិកា។ ដើម្បីឱ្យបានជោគជ័យក្នុងជីវិត យើងត្រូវការចំណេះដឹងលើមុខវិជ្ជាទាំង៤ក្នុងវិទ្យាសាស្ត្រដូចជា៖ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ។

ឯកសារនេះជាឯកសារសម្រាប់គ្រូសិក្សាស្រាវជ្រាវដោយខ្លួនឯង មានន័យថា៖ គ្រូចង់អភិវឌ្ឍចំណេះដឹង និងវិធីសាស្ត្របង្រៀនលើមុខវិជ្ជារបស់ខ្លួន ។

ក្នុងឯកសារណែនាំគ្រូនេះមានផែនការបង្រៀនមួយចំនួន និងសង្ខេបខ្លឹមសារក្នុងមេរៀនដើម្បីជួយគ្រូឱ្យស្វែងរកព័ត៌មានបន្ថែម និងមានកិច្ចតែងការបង្រៀនដែលបញ្ជ្រាបខ្លឹមសារថ្មីៗពីឯកសារយោងមួយចំនួន ដូចជា៖

- សៀវភៅណែនាំសម្រាប់គ្រូបង្រៀនរបស់គម្រោង STEPSAM3 នៃអង្គការ JICA មានគោលបំណងគាំទ្រការបង្រៀនមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រ និងមានខ្លឹមសារលម្អិតសម្រាប់មេរៀនមួយចំនួនដូចជា ៖
  - ចំណេះដឹងបន្ថែមសម្រាប់គ្រូ (មិនគួរបង្រៀនទេ)
  - ការបកស្រាយ និងការពន្យល់ទាក់ទងនឹងខ្លឹមសារពិបាក
  - សកម្មភាពបង្រៀន និងរៀនបន្ថែម
  - ចំណុចដែលត្រូវកែសម្រួលក្នុងសៀវភៅសិក្សាគោល
  - ចម្លើយសម្រាប់លំហាត់ និងហាត់ក្នុងសៀវភៅសិក្សាគោល ។

- សៀវភៅណែនាំគ្រូរបស់គម្រោង «វិទ្យាសាស្ត្រ និងបំណិនជីវិតផ្នែកបរិស្ថាន និងកសិកម្ម» SEAL របស់អង្គការ VVOB មានគោលបំណងគាំទ្រការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងមានឯកសារណែនាំគ្រូដែលមានខ្លឹមសារទាក់ទងនឹងការធ្វើពិសោធន៍សម្រាប់មុខវិជ្ជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។ ក្រៅពីនេះ SEAL ក៏មានសៀវភៅណែនាំគ្រូ គោលវិធីសិស្សមជ្ឈមណ្ឌលផងដែរ។ ឯកសារណែនាំគ្រូ «ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី២» មានរូបគំនូរតុក្កតាគំនិត (concept cartoons) ដែលជាសម្ភារៈសម្រាប់បង្កើតសកម្មភាពឱ្យសិស្សពិភាក្សាគ្នា និងដើម្បីឱ្យគ្រូវាយតម្លៃការយល់ដឹងរបស់សិស្ស។
- «សៀវភៅគាំទ្រការពិសោធន៍សម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី៧-៩» ពិសោធន៍ ល្បែងសិក្សា និងការសង្កេតរបស់អង្គការ VSO មានគោលបំណងគាំទ្រការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ រួមមានសកម្មភាពសម្រាប់មេរៀននីមួយៗស្របតាមកម្មវិធីសិក្សា រៀបចំតាមលំដាប់លំដោយដូចក្នុងសៀវភៅសិក្សាគោល និងមានសកម្មភាពសម្រាប់មេរៀនភាគច្រើន។

កិច្ចតែងការបង្រៀនក្នុងសៀវភៅនេះជាគំរូ អាចអនុវត្តតាម ឬកែសម្រួលក៏បាន ហើយមានកិច្ចតែងការបង្រៀនដទៃទៀតនៅក្នុងវេបសាយ៖ www.krou789.com វេបសាយនេះ មានឯកសារយោងមួយចំនួន ដែលពន្យល់អំពីវិធីសាស្ត្របង្រៀន និងសទ្ទានុក្រមសម្រាប់មុខវិជ្ជានីមួយៗ។

ដើម្បីបង្រៀនវិទ្យាសាស្ត្រឱ្យបានត្រឹមត្រូវ លោកគ្រូ អ្នកគ្រូមិនត្រូវបង្ហាញតែទ្រឹស្តី និងរូបមន្តប៉ុណ្ណោះទេ តែត្រូវឱ្យសិស្សចេះគិត និងធ្វើបានតាមចំណេះដឹង និងបំណិនរបស់គេផងដែរ។ គ្រូត្រូវលើកទឹកចិត្តសិស្សឱ្យមានការគិតខ្ពស់ និងគ្រូត្រូវសួរសំណួរដែលអភិវឌ្ឍបំណិនរបស់សិស្ស ។

គ្រូចង់ឱ្យសិស្សមានការចាប់អារម្មណ៍ទៅលើមុខវិជ្ជាវិទ្យាសាស្ត្រនេះ ដូចនេះហើយគ្រូត្រូវការអនុវត្តវិទ្យាសាស្ត្រពិត ដែលមានការសង្កេត និងពិសោធន៍ ពីព្រោះសកម្មភាពអនុវត្តទាំងនេះនឹងផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង ។ នៅពេលដែលសិស្សអនុវត្តសកម្មភាពតាមរយៈការដឹកនាំរបស់គ្រូ ពួកគេរៀនបំណិនថ្មី និងបង្កើតឥរិយាបថចង់សិក្សាថែមទៀត មានការច្នៃប្រឌិត និងមានសមត្ថភាពដោះស្រាយបញ្ហា ដែលជាបំណិនជីវិត ។

ក្នុង "ឯកសារណែនាំគ្រូបង្រៀន ស្តីពីវិធីសាស្ត្របង្រៀនដោយបញ្ជ្រាបខ្លឹមសារបន្ថែមពីឯកសារយោង" នេះ យើងបង្ហាញគ្រូអំពីវិធីសាស្ត្របង្រៀនមួយចំនួនដែលទាក់ទងនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានផែនការបង្រៀន និងកិច្ចតែងការបង្រៀនដែលបញ្ជ្រាបខ្លឹមសារបន្ថែមពីប្រភពផ្សេងៗ ។

ដើម្បីធានាបាននូវការបង្រៀនប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមាន**ការចូលរួមរបស់សិស្ស** ដែលមានន័យថា៖ សិស្សត្រូវធ្វើសកម្មភាព ពិសោធន៍ ល្បែងសិក្សា និងមានឱកាសពិភាក្សាគ្នា និងពន្យល់ពីគំនិតរបស់ពួកគេទៅវិញទៅមក ។ សិស្សអាចធ្វើពិសោធន៍តាមក្រុមដែលមានសមាជិកច្រើនបំផុត៦នាក់ ។

ការអនុវត្តពិសោធន៍ជាក្រុមគឺជាមធ្យោបាយវិជ្ជមានមួយដែលធ្វើឱ្យមានការលើកទឹកចិត្ត ទំនាក់ទំនងល្អ និងបង្កើតសហប្រតិបត្តិការក្នុងក្រុមសិស្ស ប៉ុន្តែគ្រូត្រូវយកចិត្តទុកដាក់តាមរយៈការរៀបចំថ្នាក់រៀនដើម្បីឱ្យការរៀនមានប្រសិទ្ធភាព ។

មូលដ្ឋានគ្រឹះនៃមុខវិជ្ជាវិទ្យាសាស្ត្រគឺ **ការធ្វើពិសោធន៍** ទ្រឹស្តីក្នុងមុខវិជ្ជារូបវិទ្យា ជីវវិទ្យា គីមីវិទ្យា និងផែនដីវិទ្យា ត្រូវបានបង្កើតឡើងតាមរយៈការធ្វើសង្កេត និងការធ្វើពិសោធន៍ ។ នៅក្នុងវិទ្យាសាស្ត្រ គ្រប់ទ្រឹស្តី និងគំរូទាំងអស់ត្រូវការបញ្ជាក់ដោយការធ្វើពិសោធន៍ ហើយដរាបណាការសង្កេត និងការធ្វើពិសោធន៍មិនបានបញ្ជាក់ពីភស្តុតាងឱ្យបានត្រឹមត្រូវ នោះទ្រឹស្តី ឬគំរូទាំងនោះមិនអាចអនុវត្តប្រកបដោយប្រសិទ្ធភាពបានឡើយ ។

នៅក្នុងការពិសោធន៍ជាញឹកញាប់យើងប្រើការវាស់ ហើយការវាស់នេះអាចធ្វើសារចុះសារឡើងបាន ។ ដូច្នេះ ប្រសិនបើគេ វាស់បរិមាណតាមលក្ខណៈដូចគ្នានោះគេត្រូវតែទទួលបានលទ្ធផលដូចគ្នា ។

នៅពេលដែលលោកគ្រូ អ្នកគ្រូអនុវត្តពិសោធន៍ ឬបង្ហាញឱ្យសិស្សមើលឃើញ គ្រូត្រូវការសម្ភារៈមួយចំនួនដែលភាគច្រើនមានតម្លៃខ្ពស់ និងមួយចំនួនមានការប្រើប្រាស់ខុស និងងាយបែកបាក់ ។ លើសពីនេះ សម្ភារៈមួយចំនួនក្នុងសៀវភៅ "សៀវភៅគាំទ្រការពិសោធន៍សម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី៧ ៨ ៩" របស់អង្គការVSO ជាសម្ភារៈសាមញ្ញ ហើយមានតម្លៃទាប ។

(អត្ថបទកែសម្រួលពីឯកសារយោង៖ "សៀវភៅគាំទ្រការពិសោធន៍សម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី៧ ៨ ៩" (VSO))

# រៀបចំបញ្ជ្រាបខ្លឹមសារថ្មីៗ

(1) ពិនិត្យតារាងទំនាក់ទំនងរវាងកម្មវិធីសិក្សា និងឯកសារយោង (ទំព័រទី.....)

សៀវភៅសិក្សាគោល ឧទាហរណ៍ មេរៀន "C712 ចំណែកថ្នាក់រូបធាតុ"

C = គីមីវិទ្យា (ភាសាអង់គ្លេស៖ Chemistry = C)

7 = ថ្នាក់ទី៧ (7)

1 = ជំពូកទី១ (1)

2 = មេរៀនទី២ (2)

(2) ពិនិត្យឯកសារយោងផ្សេងៗ ៖

| មេរៀន៖ | STEPSAM3 | រូបគំនូរតុក្កតាគំនិត VVOB | ពិសោធន៍ VVOB | ពិសោធន៍ VSO |
|---|---|---|---|---|
| C711 រូបធាតុ | សៀវភៅណែនាំគ្រូ (ទំ.4-18) | 71.អង្គធាតុរាវ (ទំ.85-87) | | លក្ខណៈរូបធាតុ(ទំ.50) |
| C712 ចំណែកថ្នាក់រូបធាតុ | សៀវភៅណែនាំគ្រូ (ទំ.23-38) | | 1.4 ការបាត់បង់មាឌ(ទំ.9-10)<br>1.14 ល្បាយនៃអង្គធាតុរាវទាំងប្រាំ (ទំ.26-27)<br>2.1 ចលនានៃបញ្ចកក្នុងល្បាយទឹកខ្មេះ និងម្សៅសូដា(ទំ.28-29)<br>2.2 អាតូមក្នុងប្រតិកម្មគីមី(ទំ.29-31) | ការបែងចែកចំណាត់ថ្នាក់ (ទំ.52)<br>ការរកអត្តសញ្ញាណកម្មផ្សេងៗ (ទំ.53)<br>ដង់ស៊ីតេ បរិមាណ(ទំ.55)<br>គំរូភាគល្អិត(ទំ.57) |

មេរៀន "C712 ចំណែកថ្នាក់រូបធាតុ"

- មានសៀវភៅណែនាំសម្រាប់គ្រូបង្រៀន របស់គម្រោង STEPSAM3 នៃអង្គការ JICA
- គ្មាន រូបគំនូរតុក្កតាគំនិត របស់អង្គការ VVOB
- មាន ពិសោធន៍ ៤ របស់អង្គការ VVOB (មេរៀន មួយចំនួនមានពិសោធន៍សម្រាប់បញ្ជាក់ ប៉ុន្តែមេរៀនមួយចំនួនគ្មានពិសោធន៍បញ្ជាក់ទេ)
- មាន ពិសោធន៍ ៤ របស់អង្គការ VSO (មេរៀនភាគច្រើនមានពិសោធន៍តែមួយ)
- គ្រូត្រូវតែជ្រើសរើសសកម្មភាពមួយ (ឬមួយចំនួន) ដែលជឿជាក់ថាអាចមានជោគជ័យ និងអាចប្រមូលសម្ភារៈបានគ្រប់គ្រាន់ទេ

គ្រូត្រូវរកសកម្មភាពបញ្ជ្រាបបន្ថែមដើម្បីកែលម្អការបង្រៀន និងរៀន ដែលធានាថា សិស្សនឹងចូលរួមបានគ្រប់ៗគ្នា ។

(3) គ្រូត្រូវសួរសំណួរគន្លឹះ ដើម្បីបញ្ជ្រាបខ្លឹមសារបន្ថែមពីសៀវភៅយោងដែលមានដូចជា ៖

(1) សកម្មភាពមានគោលបំណងឱ្យសិស្សរៀនអ្វីខ្លះ?

(2) គ្រូអាចបញ្ជ្រាបសកម្មភាពថ្មីៗនៅពេលណា? (ជំហានទី២? ទី៣? ទី៤? កិច្ចការផ្ទះ?)

(4) សាកល្បងធ្វើសកម្មភាពជាមុនសិនដើម្បីធានាបាននូវគុណភាព និងជោគជ័យក្នុងម៉ោងសិក្សា

(5) ប៉ាន់ស្មានពេលវេលា (ប៉ុន្មាននាទី)

(6) អាចមានចំនួនសិស្សប៉ុន្មាននាក់ចូលរួមបាន (កាន់តែច្រើន កាន់តែល្អ)

(7) ប្រើប្រាស់កិច្ចតែងការបង្រៀនដែលមានស្រាប់ ដើម្បីបញ្ជ្រាបខ្លឹមសារថ្មីៗពីសៀវភៅយោង

(8) ប្រាប់ពីសៀវភៅយោងឱ្យបានច្បាស់លាស់នៅក្នុងកិច្ចតែងការបង្រៀន (ឧទាហរណ៍. សៀវភៅយោង៖ រូបគំនូរតុក្កតា គំនិតទី.... (VVOB ទំព័រទី....))

(9) វាយតម្លៃ និងកត់ត្រាអ្វីដែលមានឬគ្មានជោគជ័យ... គិតពិចារណាអំពីលទ្ធផលល្អប្រសើរនៅពេលអនាគត

ពីចំណុចទី(1) ដល់ទី(9) សង្ខេបក្នុងដ្យាក្រាមនៅខាងក្រោម ៖

**ដ្យាក្រាមបង្ហាញវិធីបញ្ជ្រាបខ្លឹមសារ ៖**



## ការណែនាំទូទៅសម្រាប់ការបង្រៀនវិទ្យាសាស្ត្រ ៖

**អនុសាសន៍ ៖**

- រៀបចំសម្ភារៈទាំងអស់សម្រាប់សកម្មភាព មុនពេលចាប់ផ្តើមមេរៀន ។
- រៀបចំសម្ភារៈទាំងអស់សម្រាប់គ្រប់សកម្មភាព មុនពេលចាប់ផ្តើមមេរៀន ។
- អនុវត្តសកម្មភាពម្តងមួយជំហានៗ ដោយធ្វើតាមវិធីសាស្ត្រការបង្រៀន និងរៀន វិទ្យាសាស្ត្រតាមបែបរិះរក ។
- លើកទឹកចិត្តដល់សិស្សគ្រប់គ្នា ឱ្យធ្វើការសង្កេត សញ្ជឹងគិត ទស្សន៍ទាយ ពន្យល់ និងកត់ត្រា ។
- ជុំវិញ សម្របសម្រួល និងជួយប្រសិនបើចាំបាច់ក្នុងអំឡុងពេលសិស្សកំពុងធ្វើការជាបុគ្គល ឬជា ក្រុម។ ជួយដល់សិស្សដែលរៀនយឺត (សិស្សមិនសូវចេះ) ។
- បញ្ចូលសកម្មភាពនៅក្នុងកិច្ចតែងការបង្រៀនជាចាំបាច់ ។

**សុវត្ថិភាព ៖**

- វាគឺជាការចាំបាច់ណាស់ ដែលត្រូវគោរពតាម ច្បាប់ដូចខាងក្រោម៖
- ត្រូវពាក់អាវពិសោធ វ៉ែនតាការពារ ស្រោមដៃ និងម៉ាសការពារ ដើម្បីធានាសុវត្ថិភាពដល់គ្រូ និងសិស្ស ។
- ប្រុងប្រយ័ត្ននៅពេលកំពុងកាន់សារធាតុគីមី ឬវត្ថុរាវក្តៅ (ទឹកផងដែរ) និងជាពិសេសការការពារភ្នែក និងស្បែក ។
- អាស៊ីត និងបាស ឬសារធាតុគីមីផ្សេងៗ ដែលអាចធ្វើឱ្យខូចស្បែករបស់អ្នក ដូច្នេះសូមចាប់កាន់ដោយយកចិត្តទុកដាក់បំផុត ។
- កុំខ្ជះខ្ជាយសារធាតុគីមីត្រូវចេះលៃលកក្នុងការប្រើសារធាតុគីមីដោយសន្សំសំចៃ ។
- គួរប្រើតែអាគុយ និងថ្មពិលជាប្រភពអគ្គិសនី តែប៉ុណ្ណោះ ។ សូមកុំសាកល្បងប្រើប្រភពអគ្គិសនីផ្សេងទៀតដែលមានតង់ស្យុងខ្ពស់ ។
- ហាមភ្លក់សារធាតុអ្វីឱ្យសោះ ។
- ត្រូវទម្លាប់អនាម័យ និងលាងដៃនៅពេលសកម្មភាពត្រូវបានបញ្ចប់ សកម្មភាព ។
- គោរពតាមបទបញ្ជាផ្ទៃក្នុងមន្ទីរពិសោធជានិច្ច ។
- ហាមធ្វើការក្នុងមន្ទីរពិសោធតែម្នាក់ឯង ត្រូវមានមនុស្សធ្វើការជាមួយអ្នកជានិច្ច ។

(អត្ថបទកែសម្រួលពីសៀវភៅយោង៖ "សៀវភៅគាំទ្រការពិសោធន៍សម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី៧-៩" (VSO)

---

## វិធីសាស្ត្របង្រៀន

### ១. ការបង្រៀន និងរៀនតាមបែបរិះរក (Inquiry-Based Learning, IBL)

ការបង្រៀន និងរៀនតាមបែបរិះរក ជាវិធីសាស្ត្របង្រៀនមួយដែលប្រើប្រាស់ " សំណួរគន្លឹះ "

សំណួរគន្លឹះជាបញ្ហាមួយដែលសិស្សត្រូវការដោះស្រាយដោយប្រើវិធីវិទ្យាសាស្ត្រ (scientific method) ដើម្បីសន្និដ្ឋានឱ្យបានត្រឹមត្រូវ។ ក្នុងសៀវភៅណែនាំគ្រូនេះ កិច្ចតែងការបង្រៀនមួយចំនួនបានបញ្ចូលនូវ វិធីសាស្ត្រ " ការបង្រៀន និងរៀនតាមបែបរិះរក (IBL) "។

ក្នុងសៀវភៅណែនាំគ្រូរបស់អង្គការSTEPSAM3 និងVSO មានការណែនាំពិសោធ និងសកម្មភាពបង្រៀន និងរៀនដោយប្រើប្រាស់ " វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) "

វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) មានដំណើរការតាមលំដាប់លំដោយដូចបង្ហាញក្នុងតារាងខាងក្រោម ៖

| | |
|---|---|
| ១. កំណត់បញ្ហា (Set the problem) | - សង្កេតបាតុភូត→សំណួរភ្ជាប់→សំណួរគន្លឹះ |
| ២. សម្មតិកម្ម (Develop a hypothesis) | - ការទស្សន៍ទាយ (លទ្ធផលរំពឹងទុក) |
| ៣. ពិសោធ (Experiment) | - ប្លង់ពិសោធ → អនុវត្ត→កត់ត្រាការសង្កេត |
| ៤. វិភាគទិន្នន័យ (Analyse the information) | - លទ្ធផល និងវិភាគទិន្នន័យ |
| ៥. សន្និដ្ឋាន (Conclusion) | - សន្និដ្ឋាន (សំយោគលទ្ធផលពិសោធដែលទទួលបាន) |

អង្គការ JICA (ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) គឺជាអង្គការដែលបានណែនាំការបង្រៀន និងរៀនតាមបែបរិះរកនៅក្នុងប្រទេសកម្ពុជា និងបានបោះពុម្ពសៀវភៅ "ការណែនាំការបង្រៀន និងរៀនមេរៀនវិទ្យាសាស្ត្រតាមបែបរិះរក" (IBL) យើងគ្រាន់តែសង្ខេបលើខ្លឹមសារ IBL ដើម្បីឱ្យមានបញ្ញត្តិកាន់តែច្បាស់។

សិស្សគួរតែរៀនវិទ្យាសាស្ត្រដោយការធ្វើពិសោធន៍។ វិធីសាស្ត្រនៃការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរកគឺជាមធ្យោបាយដ៏ល្អ ក្នុងការបង្រៀនសិស្សឱ្យចេះសង្កេត និងគិតអំពីវិទ្យាសាស្ត្រ។ គ្រូមិនមែនជាអ្នកផ្តល់ឱ្យសិស្សតែមួយមុខនោះទេ ប៉ុន្តែគឺជាអ្នកដែលលើកទឹកចិត្តឱ្យសិស្សរកឃើញនូវចំណេះដឹងដោយខ្លួនឯង ។ នៅក្នុងមេរៀន IBL សិស្សត្រូវលើកជាសំណួរឡើង ហើយក៏ត្រូវគិតអំពីសំណួរនោះដែរ ។ បន្ទាប់មកសិស្ស ត្រូវធ្វើពិសោធន៍ដើម្បីឆ្លើយសំណួរ និងធ្វើការសង្កេតឱ្យបានល្អ ព្រមទាំងទាញរកសេចក្តីសន្និដ្ឋានឱ្យបានសមស្របដោយផ្អែកលើលទ្ធផលនៃការពិសោធន៍ជាមូលដ្ឋាន។

នៅពេលដែលលោកគ្រូ អ្នកគ្រូកសាងកិច្ចតែងការបង្រៀនតាមវិធីសាស្ត្រ IBL ដែលមានការពិសោធន៍ ការបង្ហាញងាយៗ ការសង្កេត ឬល្បែង មុនដំបូងត្រូវត្រួតពិនិត្យវត្ថុបំណងមេរៀនឱ្យបានច្បាស់សិន។ គ្រូចាប់ផ្តើមបង្រៀន ដោយផ្តើមពីការសង្កេតបាតុភូតហើយធ្វើការពិភាក្សាលើបាតុភូតនោះជាមួយសិស្ស។

សំណួរគន្លឹះជាលក្ខណៈពិសេសមួយរបស់ការបង្រៀន និងរៀនតាម IBL ។ គ្រូត្រូវកំណត់សំណួរគន្លឹះ នៅក្នុងកិច្ចតែងការបង្រៀន ហើយបន្ទាប់មកគ្រូត្រូវព្យាយាមបង្កើតសំណួរគន្លឹះជាមួយសិស្ស មុនពេលចាប់ផ្តើមការពិសោធន៍ ។ សំណួរគន្លឹះធ្វើឱ្យ

សិស្សទទួលបានជោគជ័យលើការសម្រេចវត្ថុបំណងនៃមេរៀន ដោយលទ្ធផលបានពីការធ្វើពិសោធន៍ត្រូវតែជាចម្លើយរបស់សំណួរគន្លឹះ។

ការណែនាំចំពោះការពិសោធន៍ និងរបៀបអនុវត្តពិសោធន៍គឺអាស្រ័យទៅលើវត្ថុបំណងមេរៀន។ ក្រោយពេលសង្កេត និងសរសេរលទ្ធផលរួច សិស្សត្រូវទាញរកសេចក្តីសន្និដ្ឋាន ដែលមានគ្រូជាអ្នកសម្របសម្រួល។

ខាងក្រោមនេះគឺជាឧទាហរណ៍ បង្រៀនវិទ្យាសាស្ត្រតាមបែបរិះរកអំពី "អុកស៊ីសែន" (C922) ។

**វត្ថុបំណងមេរៀន**

- ពន្យល់ពីទំនាក់ទំនងរវាងការឆេះជាមួយវត្តមានខ្យល់ជុំវិញ
- បកស្រាយពីទំនាក់ទំនងរវាងមាឌខ្យល់ និងរយៈពេលនៃការឆេះ
- មានបម្រុងប្រយ័ត្នក្នុងពេលធ្វើពិសោធ ។

**រំឭកមេរៀនចាស់ (៥នាទី)**

គ្រូរំឭកមេរៀនចាស់ដែលទាក់ទងនឹងឧស្ម័នអុកស៊ីសែន ដោយលើកជាសំណួរទៅកាន់សិស្ស។

**១. បាតុភូត និងការពិភាក្សា (១០នាទី)**

គ្រូបង្ហាញទៀនមួយដើមដល់សិស្ស រួចដុតទៀននោះ បន្ទាប់មកគ្រូសួរសំណួរជាបន្តបន្ទាប់ទៅកាន់សិស្ស ៖

- តើមានអ្វីកើតឡើង នៅពេលដែលទៀនកំពុងឆេះ? តើមានអ្វី បាត់បង់ និងការកកើត?
- តើគ្រប់ចំហេះដូចគ្នាដែរឬទេ?
- តើការឆេះលោហៈធាតុ (ម៉ាញ៉េស្យូម) ដូចគ្នាទៅនឹងដំណើរការឆេះរបស់ទៀនឬទេ? (គ្រូដុតម៉ាញ៉េស្យូមបង្ហាញ)
- តើត្រូវធ្វើដូចម្តេច ដើម្បីបញ្ឈប់ការឆេះ? សូមលើកឡើងនូវវិធីខុសៗគ្នា។

គ្រូត្រូវគិតអំពីចម្លើយដែលនឹងត្រូវទទួលពីសិស្ស ដើម្បីត្រៀមសកម្មភាពបន្ត ។

**សំណួរគន្លឹះ (៣នាទី)**

តើបរិមាណខ្យល់ និងចំហេះទៀនមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

**២.សម្មតិកម្ម** គ្រូបំផុសសំណួរខ្លីៗបន្ថែមដើម្បីឱ្យសិស្សមានគំនិតទស្សន៍ទាយចម្លើយទៅនឹងសំណួរគន្លឹះខាងលើ (ចម្លើយរបស់សិស្សត្រឹមត្រូវ ឬមិនត្រឹមត្រូវ គ្រូមិនត្រូវកែចម្លើយរបស់សិស្សទេ។ ចាំបានលទ្ធផល និងបកស្រាយហើយចាំប្រៀបធៀបគ្នានឹងចម្លើយសិស្ស ព្រោះជាការព្យាករណ៍ប៉ុណ្ណោះ)

**ព្យាករណ៍នៃការពិសោធ និងការបញ្ជាក់ពីការព្យាករណ៍ (៥នាទី)**

ខ្ញុំគិតថាបរិមាណខ្យល់... ទៀនឆេះបាន... ។

**៣. ប្លង់ពិសោធ និងការធ្វើពិសោធ (១៧នាទី)**

- គ្រូបំផុសសំណួរ ៖ ដើម្បីឱ្យសិស្សមានគំនិតអាចទៅធ្វើពិសោធបានគ្រូត្រូវ ឱ្យពួកគាត់គិតពីប្លង់ពិសោធ។ បន្ទាប់មកឱ្យគេបង្ហាញ

ប្លង់ពិសោធរបស់គេតាមក្រុមនីមួយៗ។ ចុងក្រោយគ្រូត្រូវសំយោគដំណើរការពិសោធន៍សមស្របក្នុងចំណោមប្លង់ពិសោធន៍ដែលបង្កើតដោយសិស្ស ឱ្យត្រូវទៅនឹងសម្ភារៈដែលគ្រូបានត្រៀមទុក។

**ពិសោធ (១៥នាទី)**

ក. គ្រូបែងចែកសិស្សជាក្រុម រួចឱ្យសិស្សតាមក្រុមនីមួយៗធ្វើពិសោធន៍ និងសង្កេត និងកត់ត្រាលទ្ធផលពិសោធ

ខ. គ្រូដើរមើល និងជួយសិស្ស ក៏ប៉ុន្តែត្រូវឱ្យសិស្សធ្វើការពិសោធន៍ដោយខ្លួនឯងផ្ទាល់(គ្រូគ្រាន់តែជាអ្នកសម្របសម្រួលប៉ុណ្ណោះ)។

**៤. លទ្ធផល និងការវិភាគទិន្នន័យ**

| ពិសោធន៍ | លទ្ធផលការសង្កេត |
|---|---|
| ១. យកកែវមកគ្របទៀន ដែលកំពុងឆេះ | |
| ២. យកកែវទំហំខុសៗគ្នា មកគ្របទៀនដែល កំពុងឆេះ | |

**៥. សន្និដ្ឋាន (៥នាទី)**

ក. គ្រូណែនាំឱ្យសិស្សគ្រប់គ្នាសរសេរសេចក្តីសន្និដ្ឋានដោយផ្អែកលើលទ្ធផលនៃការសង្កេតរបស់គេ

ខ. គ្រូដឹកនាំពិភាក្សា និងទាញយកសេចក្តីសន្និដ្ឋានរួមមួយដែលជាចម្លើយនៃសំណួរគន្លឹះ

**សង្ខេប (៥នាទី)**

គ្រូសង្ខេបមេរៀន និងត្រូវប្រាកដថា សិស្សទាំងអស់សម្រេចវត្ថុបំណងនៃមេរៀន។

---

## ២. រៀនដោយការចូលរួម

មេរៀនដែលមានប្រសិទ្ធភាពគឺមេរៀនដែលមានសកម្មភាពសិស្សចូលរួមបានច្រើន និងសិស្សទទួលបានបំណិនបន្ថែមផងដែរ ។

ខាងក្រោមនេះជា "ជណ្តើរបំណិនវិទ្យាសាស្ត្រ" ។ ជណ្តើរនេះ បង្ហាញវិធីសាស្ត្របង្រៀនតាមលំដាប់លំដោយ តាមថ្នាក់នីមួយៗ(កាន់តែខ្ពស់ កាន់តែល្អ)។ វាជាវិធីសាស្ត្រដែលឱ្យសិស្សមានឱកាសចូលរួមបានច្រើន ហើយមានប្រសិទ្ធភាពខ្ពស់ក្នុងការរៀន និងបង្កើតបំណិនថ្មីៗ ។

គ្រូត្រូវដឹកនាំសិស្សឱ្យឡើង ជណ្តើរបំណិនវិទ្យាសាស្ត្រ នៅគ្រប់មេរៀន ។ នៅកម្រិតខ្ពស់ត្រូវការពេលវេលាបន្ថែម និងជួនកាលត្រូវការសម្ភារៈបន្ថែម ដូច្នេះគ្រូត្រូវអនុវត្តទៅតាមសមត្ថភាព សម្ភារៈ និងភាពជាក់ស្តែងរបស់សិស្ស និងថ្នាក់រៀន ម្តងមួយជំហានៗ ។

**ជណ្ដើរបំណិនវិទ្យាសាស្ត្រ** (ចូរអានពីក្រោមទៅលើ)

| | វិធីសាស្ត្របង្រៀន | បំណិនដែលសិស្ស ទទួលបាន | ឧបសគ្គ |
|---|---|---|---|
| | សិស្សបង្កើតរបៀបពិសោធ (ប្លង់ពិសោធ)<br>សិស្សបង្កើតរបៀបធ្វើសកម្មភាព | ការធ្វើផែនការ (Planning) / ការបង្កើត (Creating)<br>ការសម្រេចចិត្ត (Decision-making) / ទំនាក់ទំនង (Communication)<br>សហប្រតិបត្តិការ (Co-operation) / ការព្យាករណ៍ (Prediction)<br>ការសង្កេត (Observation) /ការសំយោគព័ត៌មាន (Synthesis)<br>ការកត់ត្រាព័ត៌មាន (Recording)<br>ការបង្ហាញ និង ការបកស្រាយ (Explanation) | ត្រូវការពេលវេលាច្រើន<br>ត្រូវការសម្ភារៈច្រើន<br>មិនអាចព្យាករណ៍បាន |
| | សិស្សធ្វើពិសោធន៍តាមការណែនាំរបស់គ្រូ<br>សិស្សធ្វើសកម្មភាពតាមការណែនាំរបស់គ្រូ | ការធ្វើផែនការ / ការសម្រេចចិត្ត<br>ទំនាក់ទំនង / សហប្រតិបត្តិការ<br>ការព្យាករណ៍ / ការសង្កេត<br>ការសំយោគព័ត៌មាន / ការកត់ត្រាព័ត៌មាន<br>ការបង្ហាញ និង ការបកស្រាយ | ត្រូវការសម្ភារៈច្រើន<br>ត្រូវការពេលវេលាច្រើន<br>ដើម្បីត្រៀមបង្រៀន |
| | គ្រូធ្វើពិសោធន៍ឱ្យសិស្សសង្កេត បន្ទាប់មកសិស្សធ្វើ<br>គ្រូធ្វើសកម្មភាពឱ្យសិស្សសង្កេត បន្ទាប់មកសិស្សធ្វើ | ទំនាក់ទំនង / សហប្រតិបត្តិការ<br>ការព្យាករណ៍ / ការសង្កេត<br>ការសំយោគព័ត៌មាន / ការកត់ត្រាព័ត៌មាន<br>ការបង្ហាញ និង ការបកស្រាយ | ត្រូវការសម្ភារៈច្រើន<br>ត្រូវការពេលវេលាច្រើន<br>ដើម្បីត្រៀមបង្រៀន |
|  | គ្រូបង្ហាញឱ្យសិស្សមើល | ទំនាក់ទំនង / ការព្យាករណ៍<br>ការសង្កេត / ការសំយោគព័ត៌មាន<br>ការកត់ត្រាព័ត៌មាន / ការបង្ហាញ និង ការបកស្រាយ | ត្រូវការសម្ភារៈ<br>ត្រូវការពេលវេលាច្រើន<br>ដើម្បីត្រៀមបង្រៀន |
| | សិស្សមើលពិសោធន៍នៅវីដេអូ | ការព្យាករណ៍ / ការសង្កេត<br>ការសំយោគព័ត៌មាន / ការកត់ត្រាព័ត៌មាន<br>ការបង្ហាញ និង ការបកស្រាយ | សម្ភារៈបច្ចេកវិទ្យា |
| | គ្រូបកស្រាយដោយមានការប្រើប្រាស់រូបភាពនិងពាក្យសំដី សិស្សកត់ត្រា | ការព្យាករណ៍ / ការសង្កេត<br>ការកត់ត្រាព័ត៌មាន / ការបង្ហាញ និង ការបកស្រាយ | ត្រូវការពេលវេលាច្រើន<br>ដើម្បីត្រៀមបង្រៀន |
| | គ្រូបកស្រាយដោយមានការប្រើប្រាស់តែ ពាក្យសំដី សិស្សកត់ត្រា | ការកត់ត្រាព័ត៌មាន / ការបង្ហាញ និង ការបកស្រាយ | |
| | សិស្សសរសេរតាមគ្រូ ឬសៀវភៅ | ការកត់ត្រាព័ត៌មាន | |
| | គ្មាន | គ្មាន | គ្មាន |

## ៣. ការប្រើប្រាស់សំណួរបើក

គ្រូត្រូវសួរសំណួរបើកដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្ស ។ សំណួរបើកដែលមានផលប្រយោជន៍បំផុតគឺ ៖

(១) សំណួរដែលឱ្យសិស្សពន្យល់ បកស្រាយ

(២) សំណួរដែលចាប់ផ្ដើមដោយ ៖ " ហេតុអ្វីបានជា.... "

បើសិស្សឆ្លើយតាមការចងចាំខ្លឹមសារពីសៀវភៅ គ្រូត្រូវបញ្ជាក់ពីការយល់ដឹងរបស់សិស្ស ពីព្រោះសិស្សមួយចំនួនអាចឆ្លើយត្រឹមត្រូវ ប៉ុន្តែគេមិនទាន់យល់ច្បាស់នៅឡើយ ។ គ្រូត្រូវផ្ដល់ឱកាសដល់សិស្សក្នុងការពន្យល់ពីគំនិតរបស់ពួកគេដើម្បីបញ្ជាក់ពីការយល់ដឹង ។

គ្រូឱ្យសិស្សពិភាក្សាគ្នាជាដៃគូ ទើបជាវិធីសាស្ត្របង្រៀនមួយដ៏ល្អ ពីព្រោះសិស្សបានចូលរួមទាំងអស់គ្នា ។ ការចែកសិស្សឱ្យមានដៃគូពិភាក្សាគ្នាវាជាលទ្ធភាពល្អពីព្រោះវានឹងមិនធ្វើឱ្យសិស្សណាម្នាក់ទំនេរទេក្នុងម៉ោងសិក្សា ។

---

## ៤. វិធីជ្រើសរើសសិស្សដោយភាពយុត្តិធម៌

ដើម្បីមានយុត្តិធម៌និងសមភាព គ្រូត្រូវធានាថាសិស្ស**ទាំងអស់**មានឱកាសចូលរួមស្មើៗគ្នា

ជាទូទៅគ្រូភាគច្រើនតែងតែជ្រើសរើសសិស្សដែល ៖

- ចង់ចូលរួម
- នៅមុខ ឬកណ្ដាលថ្នាក់រៀន

សិស្សទាំងនោះតែងតែលើកដៃញឹកញាប់ ហើយមានឱកាសចូលរួមច្រើនជាងសិស្សដទៃ ប៉ុន្តែគ្រូត្រូវទទួលខុសត្រូវបង្រៀនសិស្ស**ទាំងអស់**ដូចៗគ្នា។នៅពេលដែលគ្រូសួរសំណួរ សិស្សមួយចំនួនព្យាយាមគិត និងឆ្លើយ ប៉ុន្តែសិស្សមួយចំនួន**មិនបាន**ព្យាយាមគិតដើម្បីឆ្លើយទេ។

ដូច្នេះដើម្បីធានាថាសិស្សទាំងអស់ចូលរួមគិតគ្រប់ពេលវេលា គ្រូត្រូវ៖

- សួរសំណួរតែហាមសិស្សលើកដៃ។ សិស្ស**ទាំងអស់**ត្រូវដឹងថា៖ នៅពេលដែលគ្រូសួរសំណួរ គេត្រូវគិតដើម្បីត្រៀមឆ្លើយ
- ជ្រើសរើសដោយរបៀបចៃដន្យ (ដូចជាចាប់ឆ្នោត) ដែលលឿន សាមញ្ញ និងមានយុត្តិធម៌
- ត្រូវធានាថាសិស្សមិនបានទំនេរទេក្នុងម៉ោងសិក្សា ។

---

# ៥. សកម្មភាពពិភាក្សា

ប្រសិទ្ធភាពក្នុងការសួរសំណួរបើក គឺការផ្តល់ឱកាសឱ្យសិស្សមានការគិត និងពិភាក្សាគ្នាមុនពេលឆ្លើយ ។ សកម្មភាពពិភាក្សាគ្នាគឺជាអាទិភាពព្រោះ ៖

- សិស្សរៀននៅពេលដែលគេពន្យល់គំនិតរបស់គេដល់អ្នកដទៃ
- សិស្សរៀននៅពេលដែលគេសួរ និងឆ្លើយសំណួរគ្នាទៅវិញទៅមក (សិស្សអាចបង្កើតសំណួរដោយខ្លួនឯង)
- ហេតុផលចម្លើយសំខាន់ជាងចម្លើយ (ដូចជា សកម្មភាព រូបគំនូរតុក្កតាគំនិតរបស់អង្គការ VVOB)
- សកម្មភាពពិភាក្សាត្រូវមានរយៈពេលខ្លី និងឱ្យសិស្សទាំងអស់មានឱកាសចូលរួមបានគ្រប់ៗគ្នា ។

សិស្សមានទម្លាប់ពិភាក្សាគ្នា ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ។

---

# ៦. ការប្រើប្រាស់ក្តារឆ្នួន

ក្តារឆ្នួនជាសម្ភារឧបទេសដែលប្រើប្រាស់ជាញឹកញាប់នៅថ្នាក់បឋមសិក្សា ប៉ុន្តែវាមិនត្រូវបានប្រើប្រាស់ញឹកញាប់នោះទេចាប់ពីថ្នាក់ទី៧ឡើងទៅ ។ ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន គ្រូនៅមធ្យមសិក្សាក៏អាចប្រើប្រាស់ក្តារឆ្នួនដែលជាវិធីសាស្ត្រល្អផងដែរ។

ការប្រើប្រាស់ក្តារឆ្នួនធ្វើឱ្យ ៖

- សិស្សទាំងអស់អាចឆ្លើយសំណួរមួយ ក្នុងពេលតែមួយ
- គ្រូអាចដឹងភ្លាមៗអំពីការយល់ដឹងរបស់សិស្សទាំងអស់
- សិស្សអាចឆ្លើយដោយរបៀបផ្សេងៗ ឧទាហរណ៍ សិស្សអាចឆ្លើយតាមរយៈគូររូបភាព ឬដ្យាក្រាម (ពេលខ្លះ ដ្យាក្រាមច្បាស់ជាងពាក្យសំដី)
- គ្រូអាចបង្ហាញចម្លើយល្អៗដល់សិស្សបានភ្លាមៗ ។

គ្រូអាចប្រើប្រាស់បច្ចេកទេសដើម្បីឱ្យសិស្សអាចឆ្លើយសំណួរៈ "តើប្អូនៗយល់ដល់កម្រិតណា?" ដោយការគូរជារង្វង់នៃការយល់ (ភាសាអង់គ្លេសថា៖ 'Circle of understanding') ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ចម្លើយរបស់សិស្ស |  |  |  |  |
| អត្ថន័យចម្លើយ | យល់ច្បាស់ | យល់ប៉ុន្តែត្រូវរៀនបន្ថែមទៀត | មិនសូវយល់ សូមរំឭក | មិនយល់ទេ ត្រូវការជំនួយ |

ឬគ្រូអាចប្រើប្រាស់របៀបផ្សេងៗ ដូចជា ប័ណ្ណភ្លើងសញ្ញាចរាចរណ៍ (របស់អង្គការ VVOB) ឬបើគ្មានសម្ភារៈសិស្សអាចឆ្លើយដោយសិស្សលើកមេដៃដូចខាងក្រោម ។

| ប័ណ្ណភ្លើងសញ្ញាចរាចរណ៍ | ចម្លើយរបស់សិស្ស | ព័ណ៌ ខៀវ | ព័ណ៌ លឿង | ព័ណ៌ ក្រហម |
|---|---|---|---|---|
| ឆ្លើយដោយប្រើប្រាស់មេដៃ | ចម្លើយរបស់សិស្ស |  |  |  |
| | ន័យចម្លើយ | យល់ច្បាស់ | យល់ប៉ុន្តែត្រូវរៀនបន្ថែមទៀត មិនសូវយល់ សូមរំឭក | មិនយល់ទេ ត្រូវការជំនួយ |

មានវិធីច្រើនដែលគ្រូអាចប្រើដើម្បីបញ្ជាក់ពីការយល់ដឹងរបស់សិស្ស ។

---

## ៧. ការយល់ពីការគិតរបស់សិស្ស

គ្រូបង្រៀនត្រូវណែនាំខ្លឹមសារថ្មីតាមលំដាប់លំដោយពីរូបីទៅអរូបី ។

គ្រូត្រូវចាប់ផ្តើមពី រូបីដែលមានសម្ភារៈជាក់ស្តែង ពីព្រោះសិស្សឆាប់យល់ បន្ទាប់មកគ្រូត្រូវណែនាំខ្លឹមសារថ្មីតាមលំដាប់លំដោយរហូតដល់សិស្សយល់តាម គំនិតអរូបីជាទ្រឹស្តី ពាក្យ ឬនិមិត្តសញ្ញា ដែលពិបាកជាងគេ ធ្វើឱ្យសិស្សងាយយល់ ។

នៅចន្លោះករណី រូបី និងករណី អរូបី គេហៅថា៖ ពាក់កណ្តាលរូបី (ភាសាអង់គ្លេស៖ រូបី concrete ពាក់កណ្តាលរូបី representational / iconic អរូបី abstract)

ជួនកាលគេបែងចែកពាក់កណ្តាលរូបីជា៖ ពាក់កណ្តាលរូបី (រូបថត) និងពាក់កណ្តាលអរូបី (រូបគំនូរ) ។

ពីរូបីទៅអរូបីមានជំហានច្រើនដូចដ្យាក្រាមខាងក្រោម៖

| កម្រិត | រូបី | ពាក់កណ្តាលរូបី | | | | អរូបី |
|---|---|---|---|---|---|---|
| | | ពាក់កណ្តាលរូបី | | ពាក់កណ្តាលអរូបី | | |
| ន័យ | ជាក់ស្តែង | គំរូ(វិមាត្រ) | រូបថត | រូបគំនូរ | ដ្យាក្រាម | ទ្រឹស្តី ពាក្យ និមិត្តសញ្ញា |
| | ងាយស្រួល | →→→លំដាប់បង្រៀន→→→ | | | | ពិបាក |

ចំនួនជំហានអាស្រ័យលើខ្លឹមសារមេរៀន ប៉ុន្តែគ្រូត្រូវបង្រៀនពីរូបីទៅអរូបី ។

នៅមធ្យមសិក្សាសិស្សដែលត្រូវរៀនមេរៀនអរូបី ប៉ុន្តែមិនទាន់រៀនតាមរូបីនៅបឋមសិក្សាមានបញ្ហាប្រឈម ។

ដើម្បីជួយសិស្សដែលជួបការលំបាកបែបនេះ គ្រូត្រូវពង្រឹងចំណេះដឹងរបស់ពួកគេ តាមរយៈ ៖

(១) គូររូបភាពដើម្បីផ្លាស់ពីអរូបី ទៅពាក់កណ្ដាលអរូបី ឬទៅពាក់កណ្ដាលរូបី

(២) ប្រើសម្ភារៈជាក់ស្ដែងដើម្បីផ្លាស់ពីពាក់កណ្ដាលរូបី ទៅរូបី

មានឧទាហរណ៍មួយចំនួននៅខាងក្រោម ៖

| រូបី | ពាក់កណ្ដាលរូបី | ពាក់កណ្ដាលអរូបី | អរូបី |
|---|---|---|---|
| ងាយស្រួល | | | ពិបាក |
| ទឹកខ្មេះជាក់ស្ដែង |   |   | $CH_3COOH$ 500ml |

| រូបី | ពាក់កណ្ដាលរូបី | ពាក់កណ្ដាលអរូបី | អរូបី |
|---|---|---|---|
| ងាយស្រួល | | | ពិបាក |
|   |  |   | $a^2 + b^2 = c^2$ |

| រូបី | ពាក់កណ្ដាលរូបី | ពាក់កណ្ដាលអរូបី | អរូបី |
|---|---|---|---|
| ងាយស្រួល | | | ពិបាក |
| សិស្សធ្វើ សកម្មភាព ជាក់ស្ដែង |  |   | បន្សាយ៖ ចលនារបស់ផង់ពីកន្លែងកំហាប់ខ្ពស់ទៅកន្លែងកំហាប់ទាប |

| រូបី<br>ងាយស្រួល | ពាក់កណ្ដាលរូបី | ពាក់កណ្ដាលអរូបី | អរូបី<br>ពិបាក |
|---|---|---|---|
| សិស្សពិនិត្យមើលសិលា<br>(ជាក់ស្ដែង) |  សិលាក្ដាំង<br> សិលាក្រៃ<br> សិលាដីឥដ្ឋ |  | **សិលាកម្ទេចកំណះ**<br>សិលាដីឥដ្ឋ (ក្រាម<0.004mm)<br>សិលាក្រៃ (0.06mm<ក្រាម <2mm)<br>សិលាក្ដាំង (ក្រាម>2mm) |

| រូបី<br>ងាយស្រួល | ពាក់កណ្ដាលរូបី | ពាក់កណ្ដាលអរូបី | អរូបី<br>ពិបាក |
|---|---|---|---|
|  |  |  | ផលមេកានិចនៃរ៉ក<br>$MA = F_R/F_E$ |

**សម្គាល់៖** ពេលខ្លះ ដើម្បីឱ្យសិស្សអាចឆាប់យល់ ការប្រើប្រាស់ដ្យាក្រាមដែលសាមញ្ញ មានប្រសិទ្ធភាពជាងរូបថត ឬរូបភាពជាក់ស្ដែង ។

គ្រូបង្រៀនដែលមានបទពិសោធន៍ច្រើន និងសមត្ថភាពខ្ពស់អាចឆាប់ចេះ ឬ អនុវត្តបំណិនថ្មីៗបានដោយងាយស្រួល ។ ពេលខ្លះ គ្រូដែលមានសមត្ថភាព និងចំណេះដឹងខ្ពស់ពិបាកយល់អំពីការលំបាករបស់សិស្ស ។ ដើម្បីឱ្យគ្រូអាចងាយយល់អំពីការលំបាករបស់សិស្សនៅក្នុងការទទួលយកនូវបំណិនថ្មី គ្រូអាចសាកល្បងអនុវត្តសកម្មភាពនៅក្រៅម៉ោងសិក្សាដោយប្រើដៃឆ្វេងចំពោះគ្រូដែលប្រើដៃស្ដាំជាប្រចាំ។

**សម្គាល់៖** ដើម្បីមានភាពរីកចម្រើននៅក្នុងការរៀន សិស្សត្រូវមានសកម្មភាពចូលរួម ... កាន់តែច្រើន កាន់តែល្អ

## ៨. ការប្រៀបប្រដូច និងគំរូតាង

ការប្រៀបប្រដូចគឺជាទំនាក់ទំនងភាសារវាងវត្ថុពីរ ដែលហាក់ដូចជាមិនជាប់ទាក់ទងគ្នា ។ ក្នុងការអប់រំ ការប្រៀបប្រដូចជានិច្ចជាកាលជាការភ្ជាប់ទំនាក់ទំនងរវាងបញ្ញត្តិថ្មីដែលសិស្សមិនធ្លាប់ដឹងទៅនឹងវត្ថុដែលសិស្សធ្លាប់ដឹងស្គាល់រួចមកហើយ ។ ការភ្ជាប់ទំនាក់ទំនងប្រភេទនេះមានសារសំខាន់ណាស់សម្រាប់ការអប់រំវិទ្យាសាស្ត្រ និងគណិតវិទ្យា ព្រោះមានចំណេះដឹងជាច្រើនដែលសិស្សមិនធ្លាប់បានជួបប្រទះដូចជា សែន ថាមពល និងអាតូមជាដើម ។

ក្រៅពីអត្ថប្រយោជន៍ ក្នុងការពន្យល់បញ្ញត្តិពិបាកៗឱ្យបានច្បាស់លាស់ ការប្រៀបប្រដូចក៏បំផុសបំណិនគិតកម្រិតខ្ពស់មួយចំនួនដូចជាបំណិនដោះស្រាយបញ្ហា និងការគិតប្រកបដោយភាពឆ្នៃប្រឌិតផងដែរ ។ ការប្រៀបប្រដូចបង្កើតឱ្យមានបរិយាកាសសប្បាយរីករាយក្នុងថ្នាក់រៀន ដែលជំរុញទឹកចិត្តសិស្សឱ្យចង់សិក្សា ។

ការអនុវត្តន៍ការប្រៀបប្រដូចទទួលបានលទ្ធផលល្អបំផុតជាមួយការសិក្សារបស់សិស្ស។ ពេលដែលសិស្សត្រូវបានទាក់ទាញឱ្យចូលរួមពិភាក្សា ហើយកាន់តែប្រសើរជាងនេះទៅទៀតនោះគឺពេលដែលសិស្សអាចបង្កើតការប្រៀបប្រដូចបានដោយខ្លួនឯង ។ យើងមិនគួរចាត់ទុកការប្រៀបប្រដូចត្រឹមតែជាការប្រៀបធៀបវត្ថុ ២ប៉ុណ្ណោះទេ ប៉ុន្តែគឺជាឱកាសដើម្បីពិភាក្សាឱ្យបានស៊ីជម្រៅអំពីបញ្ញត្តិពាក់ព័ន្ធផ្សេងៗ ។

ពេលខ្លះ ការប្រៀបប្រដូចប្រៀបបាននឹងអាវុធមុខពីរ ។ បើតាមន័យវិជ្ជមាន ការប្រៀបប្រដូចផ្តល់ឱកាសច្រើនសម្រាប់ការសិក្សាបែបសិស្សមជ្ឈមណ្ឌល ។ ផ្ទុយទៅវិញប្រសិនបើមិនបានប្រើដោយប្រុងប្រយ័ត្នទេ ការប្រៀបប្រដូចអាចបង្កើតគំនិតភាន់ច្រឡំថ្មី ឬធ្វើឱ្យការភាន់ច្រឡំដែលមានស្រាប់កាន់តែភាន់ច្រឡំខ្លាំងឡើង ។ គ្រប់ការប្រៀបប្រដូចទាំងអស់មានបញ្ហាត្រង់ចំណុចមួយ គឺឱ្យសិស្សបានដឹងច្បាស់ ។ ឧទាហរណ៍ ពេលដែលគ្រូប្រៀបធៀបអង្គធាតុរឹងទៅនឹងសិស្សម្នាក់ដែលអង្គុយនៅតុរបស់គេក្នុងថ្នាក់ ហើយប្រៀបធៀបអង្គធាតុរាវទៅនឹងសិស្សដែលកំពុងធ្វើសកម្មភាពជាក្រុមនៅក្នុងថ្នាក់ សិស្សអាចសន្និដ្ឋានច្រឡំថាភាគល្អិតនៃអាតូមប្រៀបបាននឹងភាវរស់តូចៗ ដែលមានសកម្មភាពដោយចេតនា ។

សៀវភៅនេះណែនាំយ៉ាងខ្លីអំពីការប្រៀបប្រដូច ប៉ុន្តែមានខ្លឹមសារបន្ថែមលម្អិតនៅក្នុងសៀវភៅ " VVOB SEAL ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី៣" ជំពូកទី៥ ។

វិធី៖ ត្រៀម អនុវត្ត វាយតម្លៃ (FAR ៖ Focus – Action – Reflection) ផ្តល់នូវយុទ្ធសាស្ត្រដែលត្រូវបានត្រៀមទុកជាមុនយ៉ាងយកចិត្តទុកដាក់ ធ្វើយ៉ាងណាឱ្យការប្រៀបប្រដូចចូលរួមសម្រេចវត្ថុបំណងមេរៀន និងផ្តល់នូវអត្ថប្រយោជន៍សម្រាប់សិស្សច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ សកម្មភាពនេះផ្តល់ឱ្យគ្រូនៅគោលការណ៍មួយដើម្បីអនុវត្តការប្រៀបប្រដូចក្នុងថ្នាក់រៀនបានជោគជ័យ ។ សកម្មភាពនេះរួមមានសកម្មភាពគ្រូនិងសិស្សនៅមុនពេលបង្រៀន ពេលកំពុងបង្រៀន និងការវាយតម្លៃក្រោយពេលបង្រៀនចប់ ។

តារាងខាងក្រោមសង្ខេបជំហានសំខាន់ៗ ក្នុងវិធីសាស្ត្រ FAR ៖

| | |
|---|---|
| 1. ត្រៀម (ជាផ្នែកមួយនៃដំណាក់កាលរៀបចំមេរៀន) | |
| បញ្ញត្តិ | តើបញ្ញត្តិ (មេរៀន) ពិបាក ឬអរូបីណាមួយដែលខ្ញុំចង់បង្រៀនសិស្ស? |
| សិស្ស | តើសិស្សមានចំណេះដឹងដែលពួកគេមានស្រាប់អ្វីខ្លះទាក់ទងនឹងបញ្ញត្តិនេះ? |
| វត្ថុប្រដូច | តើសិស្សស្គាល់វត្ថុប្រដូចនេះហើយឬនៅ? |
| 2. អនុវត្ត (ជាផ្នែកមួយនៃសកម្មភាពបង្រៀន) | |
| ដូច | តើបញ្ញត្តិនិងវត្ថុប្រដូចមានចំណុចដូចគ្នាអ្វីខ្លះ? |
| មិនដូច | តើបញ្ញត្តិនិងវត្ថុប្រដូចមានចំណុចខុសគ្នាអ្វីខ្លះ? |
| 3. វាយតម្លៃ (សម្រាប់អនុវត្តក្រោយបង្រៀនចប់) | |
| សន្និដ្ឋាន | តើការប្រៀបប្រដូចនេះច្បាស់លាស់ និងមានប្រសិទ្ធិភាពដែរឬទេ? ឬបែរជាពិបាកយល់ទៅវិញ? |
| ការកែលម្អ | តើមានចំណុចណាខ្លះគួរកែលម្អនៅពេលប្រើការប្រៀបប្រដូចនេះក្នុងការបង្រៀនលើកក្រោយ ? |

(អត្ថបទកែសម្រួលពីសៀវភៅយោង៖ "ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី៣" ជំពូកទី៥ របស់ គម្រោង SEAL នៃអង្គការ VVOB)

---

## ៩. ត្រូវសាកល្បង ហើយព្យាយាមរហូតទទួលបានជោគជ័យ

សុភាសិតអង់គ្លេសមួយពោលថា ៖ " If at first you don't succeed – try, try again " បើសិនជាអ្នកសាកល្បងលើកទីមួយគ្មានជោគជ័យ អ្នកត្រូវតែព្យាយាមសាកល្បងពីរដងទៀត ។

ជាទូទៅការសាកល្បងសកម្មភាពអ្វីមួយថ្មីតែងតែទទួលបានជោគជ័យដែលមានកម្រិត ឬបរាជ័យតែម្តង ។ ការបរាជ័យនេះ **មិនមែនជាកំហុសរបស់យើងទេ** គឺមកពីយើងមិនទាន់មានទម្លាប់ល្អ ។ បើនៅក្នុងបរិបទក្នុងការធ្វើពិសោធន៍វិញ យើងទទួលបានលទ្ធផលមិនល្អ នោះក៏**មិនមែនជាកំហុសរបស់គ្រូ និងសិស្សទេ** ។ បញ្ហាមួយចំនួនមកពីសិស្សដែលគ្មានទម្លាប់ក្នុងការរៀនដោយប្រើវិធីសាស្ត្រថ្មីៗ ប៉ុន្តែនៅពេលគ្រូជួយសម្របសម្រួល និងប្រើប្រាស់វិធីសាស្ត្រដដែលៗ សិស្សនឹងអាចទទួលបាននូវគំរូរបស់គ្រូ ហើយទទួលបានជោគជ័យបានល្អប្រសើរក្នុងការសិក្សា ។

យើងស្នើសុំឱ្យលោកគ្រូ អ្នកគ្រូ លោកនាយក នាយិកាសាលា និងក្រុមអធិការមានភាពទន់ភ្លន់ទៅតាមសកម្មភាពក្នុងម៉ោងសិក្សា ពីព្រោះគ្រូត្រូវកែសម្រួលពេលវេលា សកម្មភាពសិក្សាតាមសមត្ថភាព និងការយល់ដឹងជាក់ស្តែងរបស់សិស្ស។ ពេលខ្លះសិស្សមួយចំនួនមិនទាន់យល់ខ្លឹមសារមេរៀនចាស់ គ្រូត្រូវរំឭកខ្លឹមសារមេរៀនចាស់ឡើងវិញដើម្បីឱ្យសិស្សងាយស្រួលយល់ខ្លឹមសារមេរៀនថ្មីបានឆាប់រហ័ស ។

---

## តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៧

| មេរៀន៖ | STEPSAM3 | រូបគំនូរតុក្កតាគំនិត VVOB | ពិសោធន៍ VVOB | ពិសោធន៍ VSO |
|---|---|---|---|---|
| C711 រូបធាតុ | សៀវភៅណែនាំគ្រូ (ទំ.4-18) | 71.អង្គធាតុរាវ(ទំ.85-87) | | លក្ខណ:រូបធាតុ(ទំ.50) |
| C712 ចំណែកថ្នាក់រូបធាតុ | សៀវភៅណែនាំគ្រូ (ទំ.23-38) | | 1.4 ការបាត់បង់មាឌ(ទំ.9-10)<br>1.14 ល្បាយនៃអង្គធាតុរាវទាំងប្រាំ(ទំ.26-27)<br>2.1 ចលនានំបញ្ចុកក្នុងល្បាយទឹកខ្មេះ និងម្សៅស្ងួដា(ទំ.28-29)<br>2.3 អាតូមក្នុងប្រតិកម្មគីមី(ទំ.29-31) | ការបែងចែកចំណាត់ថ្នាក់(ទំ.52)<br>ការរកអត្តសញ្ញាណកម្មផ្សេងៗ(ទំ.53)<br>ដង់ស៊ីតេ បរិមាណ(ទំ.55)<br>គំរូភាគល្អិត(ទំ.57) |
| C721 បំលែងភាពរូបនៃរូបធាតុ | សៀវភៅណែនាំគ្រូ (ទំ.40-52) | 74. កំណជាញើស(ទំ.87)<br>75. ទឹកកករលាយ(ទំ.88) | 1.3 បម្រែបម្រួលភាពរូប និងការសង់ក្រាហ្វបម្រែបម្រួលសីតុណ្ហភាព(ទំ.7-8)<br>1.5 ភាគល្អិតនៃរូបធាតុ(ទំ.11-12) | ការផ្លាស់ប្តូរវត្ថុរាវ និងចំហាយទឹក(ទំ.58)<br>ការបំលែង និងដង់ស៊ីតេ(ទំ.59)<br>ចំហាយភាយឧស្ម័ន(ទំ.60)<br>ការបំលែងទឹកកក និងទឹក(ទំ.61) |
| C722 កត្តានៃបំលែងភាពរូប | សៀវភៅណែនាំគ្រូ (ទំ.56-67) | 79. អាស្ពីរីន(ទំ.93) | | លក្ខណ:រូប និងលក្ខណ:គីមី(ទំ.63) |
| C731 ខ្យល់ | សៀវភៅណែនាំគ្រូ (ទំ.72-85) | | | ខ្យល់ដង្ហើមចេញ(ទំ.65)<br>វត្តមានខ្យល់អុកស៊ីហ្សែន(ទំ.66)<br>វត្តមានកាបូនឌីអុកស៊ីត(ទំ.67)<br>អុកស៊ីហ្សែន និងដែក(ទំ.69) |
| C732 ធាតុកខ្វក់ខ្យល់ | សៀវភៅណែនាំគ្រូ (ទំ.91-103) | | | ការបំពុលខ្យល់(ទំ.70) |

## តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៨

| មេរៀន៖ | STEPSAM3 | រូបគំនូរតុក្កតាគំនិត VVOB | ពិសោធន៍ VVOB | ពិសោធន៍ VSO |
|---|---|---|---|---|
| C811 អាតូមនិងម៉ូលេគុល | សៀវភៅណែនាំគ្រូ (ទំ.7-15) | | | ទហំអាតូម និងម៉ូលេគុល (ទំ.159) |
| C812 និមិត្តសញ្ញា រូបមន្តគីមី និងប្រតិកម្មគីមី | សៀវភៅណែនាំគ្រូ (ទំ.19-32) | | | ល្បែងឡូតូធាតុគីមី(ទំ.162)<br>វ៉ាឡង់(ទំ.164)<br>សមិការគីមី និងគំរូអាតូម(ទំ.165) |
| C813 ធាតុ អង្គធាតុសុទ្ធ និងសមាសធាតុ | សៀវភៅណែនាំគ្រូ (ទំ.35-47) | | | ធ្វើម៉ូលេគុលជាមួយនឹងគំរូអាតូមិច(ទំ.166-167) |
| C821 ល្បាយ | សៀវភៅណែនាំគ្រូ (ទំ.52-61) | 72. ស៊ុតក្រឡុក(ទំ.86) | 1.9 ល្បាយម្សៅមី និងអំបិល(ទំ.18-19)<br>1.14 ល្បាយនៃអង្គធាតុរាវទាំងប្រាំ(ទំ.26-27) | ល្បាយ(ទំ.167) |
| C822 ញែកល្បាយ | សៀវភៅណែនាំគ្រូ (ទំ.64-75) | 73. ទឹកល្អក់(ទំ.86) | 1.1 វិធីសាស្ត្រ ការញែកល្បាយ(ទំ.2-4)<br>1.10 ការញែកល្បាយតាមការច្រោះនិងកំណកក្រាម (ទំ.19-20)<br>1.11 ការបង្កើតស្ករគ្រាប់(ទំ.21-22) | បច្ចេកទេសញែកធាតុ(ទំ.169) |
| C831 ទឹក | សៀវភៅណែនាំគ្រូ (ទំ.79-80) | | 1.7 ទឹក: ល្បាយឬអង្គធាតុសុទ្ធ(ទ.14-16) | ការផលិតទឹកសុទ្ធ(ទំ.171-172) |
| C832 សមាសភាពទឹក | សៀវភៅណែនាំគ្រូ (ទំ.92-104) | | 1.7 ទឹក: ល្បាយឬអង្គធាតុសុទ្ធ(ទំ.14-16) | អគ្គិសនីវិភាគទឹក(ទំ.173) |
| C833 សូលុយស្យុង | សៀវភៅណែនាំគ្រូ (ទំ.108-124) | 75. ការរលាយ(ទំ.88) | 1.3 បម្រែបម្រួលភាពរូប និងការសង់ក្រាហ្វបម្រែបម្រួលសីតុណ្ហភាព(ទំ.7-8)<br>1.8 សូលុយស្យុង និងកករវិលវល់(ទំ.16-18)<br>1.9 ល្បាយម្សៅមី និងអំបិល(ទំ.18-20)<br>1.12 ការបង្កើតក្រាមអំបិល(ទំ.23-24)<br>1.13 ភាពរលាយរបស់ដុំស្ករស(ទំ.24-25) | ភាគរយម៉ាស(ទំ.175)<br>ភាគរយម៉ាសទឹកសមុទ្រ(ទំ.176) |

# តារាងទំនាក់ទំនង ឯកសារយោង ៖ ថ្នាក់ទី៩

| មេរៀន៖ | STEPSAM3 | រូបគំនូរតុក្កតាគំនិត VVOB | ពិសោធន៍ VVOB | ពិសោធន៍ VSO |
|---|---|---|---|---|
| C911 តារាងខួប នៃធាតុគីមី | សៀវភៅណែនាំគ្រូ (ទំ.5-37) | | | តារាងខួបធាតុគីមី(ទំ.272) |
| C912 លក្ខណៈ ធាតុតាមក្រុម | សៀវភៅណែនាំគ្រូ (ទំ.40-50) | | | ការបង្កើតធាតុមួយ(ក្លរីន)(ទំ.274)<br>លក្ខណៈនៃធាតុក្នុងក្រុម(ទំ.275) |
| C921 កាបូន | សៀវភៅណែនាំគ្រូ (ទំ.55-66) | | | កាបូន(ទំ.279) |
| C922 អុកស៊ីសែន | សៀវភៅណែនាំគ្រូ (ទំ.70-84) | 80. ទៀនកំពុងឆេះ (ទំ.94) | 2.10 ការដុតល្បាយអាល់កុល និងទឹក(ទំ.42-43) | អុកស៊ីសែន(ទំ.281) |
| C923 អ៊ីដ្រូសែន | | | | អ៊ីដ្រូសែន(ទំ.284) |
| C931 អុកស៊ីត | សៀវភៅណែនាំគ្រូ (ទំ.89-97) | | 2.1 ចលនានំបញ្ចុកក្នុងល្បាយទឹកខ្មេះ និងម្សៅសូដា(ទំ.28-29)<br>2.2 អាតូមក្នុងប្រតិកម្មគីមី(ទំ.29-30)<br>2.3 ប៉ោងប៉ោងលើមាត់ដប(ទំ.31-32)<br>2.7 ការបង្កើតពពុះរវាងអំបិល និងភេសជ្ជៈកូកាកូឡា(ទំ.37-38)<br>2.8 ប្រតិកម្មក្នុងប្រអប់ហ្វីលថតរូប(ទំ.38-39) | អុកស៊ីត/អំបិលទង់ដែង(ទំ.286) |
| C932 អាស៊ីត | សៀវភៅណែនាំគ្រូ (ទំ.101-111) | 76. ក្រូចមានជាតិអាស៊ីត(ទំ.90) | 2.5 ស៊ុតក្នុងទឹកខ្មេះ(ទំ.34-35)<br>2.6 អំពើនៃអាស៊ីតផូស្វរិចក្នុងភេសជ្ជៈកូកាកូឡាជាមួយឆ្អឹងឬធ្មេញ(ទំ.36-37)<br>2.12 កត្តាដែលជះឥទ្ធិពលដល់ការឡើងច្រេះនៃដែក(ទំ.46-47)<br>2.14 ភ្នាក់ងារសម្អាតច្រេះ(ទំ.49-50)<br>2.15 ប្រតិកម្មបញ្ចេញកម្តៅ(ទំ.51-52) | អាស៊ីត(ទំ.289) |
| C933 បាស | សៀវភៅណែនាំគ្រូ (ទំ.115-126) | | 2.11 តេស្តលក្ខណៈបាស និងអាស៊ីតនៃសារធាតុមួយចំនួន(ទំ.43-46) | បាស(ទំ.291)<br>បាស និងអាស៊ីត(ទំ.293) |
| C934 អំបិល | សៀវភៅណែនាំគ្រូ (ទំ.130-143) | | 2.5 ស៊ុតក្នុងទឹកខ្មេះ(ទំ.34-35) | អំបិល(ទំ.295) |

## ផែនការបង្រៀន (C722)

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៧
- ជំពូកទី២ ៖ បំលែងរូបធាតុ
- រយៈពេល ៖ ០៧ម៉ោងសិក្សា

### I. វត្ថុបំណង ៖

- ពណ៌នាពីកត្តាដែលនាំឱ្យមានបំលែងរូបធាតុ
- ពណ៌នាពីបំលែងដោយកម្តៅ ពន្លឺ អគ្គិសនី និងដោយល្បាយ
- រៀបរាប់ពីសារប្រយោជន៍នៃប្រតិកម្មគីមី ។

### II-ផែនកាបង្រៀន

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល ៤ ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន**

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. សង្កេត | 124 |
| 3 | 2. បំលែងដោយកំដៅ | 125 |
| 1 | 3. បំលែងដោយពន្លឺ<br>4. បំលែងដោយអគ្គិសនី<br>5. បំលែងដោយល្បាយ | 127 |
| 1 | 6. ប្រតិកម្មគីមី | 127 |
| 1 | សង្ខេបមេរៀន និងសំណួរ | 128 |

សៀវភៅយោង ៖ ស.ស. / STEPSAM3:

### III. ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីឱ្យសិស្សអាចយល់ពីការប្រែប្រួលផ្សេងៗដែលកើតមានក្នុងធម្មជាតិជាបំលែងរូបធាតុ និងបាតុភូតដែលមានសារៈប្រយោជន៍នៃកត្តាបំលែងរូបធាតុ។

### IV. ខ្លឹមសារពិបាក ៖

ក្នុងមេរៀននេះ អាចមានការភាន់ច្រលំរវាងបំលែងភាពរូប និងបំលែងគីមី ។

. បំលែងភាពរូប គឺជាបម្រែបម្រួលទាំងឡាយណាដែលខូចទ្រង់ទ្រាយ ទម្រង់ ប៉ុន្តែវានៅរក្សាលក្ខណៈសារធាតុដើមដដែល ។ ឧទាហរណ៍ : បំណែកក្រដាសនៅតែមានលក្ខណៈជាក្រដាស ។

. បំលែងគីមី គឺជាបម្រែបម្រួលទាំងឡាយណាដែលមិនអាចរក្សាលក្ខណៈនៃសារធាតុដើមបាន ។

ឧទាហរណ៍ : ចំហេះក្រដាស បង្កើតបានផេះដែលមានលក្ខណៈខុសពីក្រដាស។

## V. ពិសោធ និងសម្មភាពបន្ថែម ៖

សៀវភៅយោង៖ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧ របស់ STEPSAM3 "កត្តានៃបំលែងរូបធាតុ"

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| - ទៀន<br>- ដែកកេះ ឬឈើគូស | ១នាទី | ២នាទី | ស្រួល | សិស្សចូលរួម |
| - កំសៀវ<br>- ចង្រ្កានហ្គាស<br>- ដែកកេះ ឬឈើគូស | ១នាទី | ៣នាទី | ស្រួល | សិស្សចូលរួម |
| - ដង្កៀប<br>- បំពង់សាក<br>- ក្រាមអ៊ីយ៉ូត<br>(សម្ភារពិសេស) | ២នាទី | ២នាទី | ស្រួល<br>(បើមានក្រាមអ៊ីយ៉ូត)<br>(វេដីអូនៅវេបសាយ) | សិស្សចូលរួម |
| - ចង្កៀងអាល់កុល<br>- ជើងទម្រ<br>- បន្ទះអាមីញ៉ង់<br>- ចានទាប<br>- ស្ករ | ៥នាទី | ៥នាទី | មធ្យម | សិស្សចូលរួម |
| - កែវបាឡុង<br>- ទឹក<br>- ចង្រ្កានហ្គាស | ២នាទី | ៥នាទី | ស្រួល | សិស្សចូលរួម |
| - ម៉ៃ្យដែក<br>- ស្ពាន់ធ័រ<br>- ចង្រ្កានហ្គាស<br>- ចានថ្ម<br>- មេដែក | ៥នាទី | ១០នាទី | ពិបាក | សិស្សចូលរួម |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមានមធ្យោបានអនុវត្ត នោះនឹងទទួលមានលទ្ធផលសិក្សាល្អ ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៧
- ជំពូកទី២ ៖ បំលែងរូបធាតុ
- មេរៀនទី២ ៖ កត្តានៃបំលែងរូបធាតុ
- ម៉ោងទី១
- ប្រធានបទ ៖

**សង្ខេត**

- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

**I. វត្ថុបំណង :**

- ចំណេះដឹង : ពណ៌នាពីការប្រែប្រួលផ្សេងៗដែលកើតមានក្នុងធម្មជាតិជាបំលែងរូបធាតុ និង ពិចារណាពីកត្តាផ្សេងៗដែលបង្កឱ្យមានបំលែងទាំងនោះតាមរយៈសំណួរពិភាក្សាក្រុមបានត្រឹមត្រូវ
- បំណិន : កំណត់ពីកត្តាផ្សេងៗដែលបណ្តាលឱ្យមានបំលែងរូបធាតុតាមរយៈការសង្កេតរូបភាព និង បាតុភូតផ្សេងៗទៀតក្នុងជីវភាពប្រចាំថ្ងៃបានត្រឹមត្រូវ
- ឥរិយាបថ : បំផុសគំនិតសិស្សឱ្យមានបម្រុងប្រយ័ត្នចំពោះបំលែងរូបធាតុទាំងឡាយដែលមានគ្រោះថ្នាក់ ។

**II. សម្ភារៈបង្រៀន និងរៀន :**

**- សៀវភៅយោង :**

+ សៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី 122 ដល់ទំព័រទី 124

+ សៀវភៅណែនាំគ្រូ ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល (VVOB) ផ្នែកទី២ រូបគំនូរតុក្កតាគំនិត ទី71 "អង្គធាតុរាវ"

+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧របស់ STEPSAM3 ទំព័រទី 56 ។

**- សម្ភារៈពិសោធន៍/សម្ភារឧបទេស :**

+ ផ្ទាំងរូបភាពមានចំនួន៤

*** កំណត់សម្គាល់ :**

+ វិធីបង្រៀន និងរៀនតាមបែបរិះរក (IBL)

III. សកម្មភាពបង្រៀន និងរៀន :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
| --- | --- | --- |
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្ដាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួលឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -គ្រូបង្ហាញរូបគំនូរតុក្កតាគំនិតរបស់ VVOB រូបទី៧១ ឱ្យសិស្ស មើល រួចបំផុសសំណួរឱ្យសិស្សគិត ពិភាក្សា និងឆ្លើយ ។<br><br>-គ្រូបំផុសសំណួរដូចជា ៖<br><br>១.ដូចម្ដេចដែលហៅថារូបធាតុ?<br><br>២.តើរូបធាតុមានភាពរូបអ្វីខ្លះ?<br><br>៣.ចូរប្រាប់ឈ្មោះបំលែងភាពរូបខាងក្រោម ៖<br>ក. រឹង→រាវ<br>ខ. រាវ→ឧស្ម័ន | ជំហានទី២ (៥នាទី)<br>**រំលឹកមេរៀនចាស់**<br><br>សៀវភៅយោង៖ VVOB ផ្នែកទី២ រូបគំនូរតុក្កតាគំនិត ទី៧១ "អង្គធាតុរាវ"<br> | -សិស្សសង្កេត គិត និងឆ្លើយតាមការយល់ឃើញរបស់ពួកគេ ។<br>ចំណុច៖ ដីខ្សាច់អាចហូរបាន ប៉ុន្តែមិនមែនជាវត្ថុរាវទេ ពីព្រោះដីខ្សាច់មានក្រាមរឹងច្រើន<br>**សម្គាល់៖** បើមានដីខ្សាច់ គ្រូអាចបង្ហាញតាមជាក់ស្ដែង<br><br>-សិស្សគិត ហើយឆ្លើយ<br>សិស្សពិភាក្សាគ្នាជាដៃគូ<br>(សិស្សប្រើក្ដារឆ្នួន)<br>(សិស្សអាចគូររូបភាពជាចម្លើយ)<br>១.រូបធាតុជាភាវៈទាំងឡាយដែលម៉ាសនិងមានឧតាំងក្នុងលំហ។<br>២.រូបធាតុមានភាពរូប រឹង រាវ និង ឧស្ម័ន្ទ។<br>៣.ក. រលាយ<br>ខ. រំហួត<br>គ. កំណញើស<br>ឃ. កំណក |

| | | |
|---|---|---|
| គ. ឧស័ន្ទ→រាវ<br>ឃ.រាវ→រឹង<br>៤.តើនៅក្នុងធម្មជាតិមានបំលែងរូបធាតុអ្វីខ្លះទៀត?<br><br>-គ្រូសួរសំណួរភ្ជាប់មេរៀនថ្មី<br>-ហេតុអ្វីបានជាកើតមានបំលែងទាំងនោះ?<br>ថ្ងៃនេះយើងសិក្សាអំពីកត្តាបំលែងរូបធាតុ។ | | ៤.នៅក្នុងធម្មជាតិមានបំលែងរូបធាតុដូចជា អំបិលរលាយក្នុងទឹក អង្ករក្លាយជាបាយដើមឈើងាប់...។ល។<br>-សិស្សគិត និងពិភាក្សាគ្នា<br>-បានជាកើតមានបំលែងទាំងនោះបណ្តាលមកពី កត្តាសីតុណ្ហភាព (សំខាន់ជាងគេ) កត្តាពន្លឺ កត្តាកម្លាំង |
| -ចែកសិស្សជាក្រុមតាមរយៈការចាប់ឆ្នោតជាដៃគូ/ក្រុមតូច<br>-ប្រាប់សិស្សតាមក្រុមឱ្យសង្កេតមើលរូបភាពក្នុងសៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី124 ត្រង់ចំណុច<br>**1.សង្កេត**<br>-បំផុស និងសរសេរសំណួរលើក្តារខៀន ៖<br>១.តើមានអ្វីកើតឡើងចំពោះពិសោធរូបទី១?<br>២.ហេតុអ្វីបានជាមានបន្ទុះនេះកើតឡើង? | ជំហានទី៣ (៣០នាទី)<br>មេរៀន **កត្តានៃបំលែងភាពរូប**<br><br>ប្រធានបទ សង្កេត (រូបភាព)<br><br>រូបភាពក្នុងសៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី124 (ខាងក្រោម)<br>**រូបភាពទី១**<br> | -អង្គុយតាមក្រុមតាមការចាត់ចែងរបស់គ្រូ ។<br>-បើកសៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី124 មើល គិត ពិភាក្សាគ្នាដើម្បីឆ្លើយសំណួររបស់គ្រូ ។<br><br>១.បង្កឱ្យមានបន្ទុះកើតឡើង<br><br>២.ដុតកម្តៅលឿនពេក<br>-ផលិតជាឧស្ម័ន<br>-ប្រតិកម្មបញ្ចេញកម្តៅខ្លាំងធ្វើឱ្យសារធាតុរាវរងនូវរំហួតយ៉ាងឆាប់រហ័ស ។ល។ |

| | | |
|---|---|---|
| -ឱ្យសិស្សសង្កេតមើលរូបភាពទី២ បន្តទៀតដោយផ្តល់ជាសំណួរ<br><br><br><br><br><br>៣.តើមានបំលែងអ្វីខ្លះកើតឡើង?<br><br><br><br><br>៤.តើកត្តាអ្វីខ្លះដែលនាំឱ្យមានបំលែងទាំងនេះកើតឡើង?<br><br><br><br>៥.ចូរលើកយកបំលែងរូបធាតុណាមួយដែលប្អូនជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ និងប្រាប់ពីមូលហេតុរបស់វាផង ។<br><br><br><br><br>-សរុបមក តើបំលែងរូបធាតុកើតឡើង ដោយកត្តាអ្វីខ្លះ?<br>-ឱ្យសិស្សធ្វើការសន្និដ្ឋានរួម បន្ទាប់មកកត់ខ្លឹមសារលើក្តារខៀន រួចឱ្យសិស្សកត់ត្រាចូលសៀវភៅ | **រូបភាពទី២**<br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br>-ដូច្នេះបំលែងរូបធាតុអាចកើតឡើងដោយសារកត្តា<br>ផ្សេងៗដូចជា កម្តៅ ពន្លឺ<br>អគ្គិសនី...។ល។ | -បន្តមើលរូបភាពទី២ គិត ពិភាក្សាគ្នាឆ្លើយសំណួរតាមរយៈការប្រើក្តារឆ្នួន<br><br><br><br><br>៣.សក់ដុះឡើង ផ្ការីកស្រស់ដោយសារទឹក ហើយផ្កាស្វិតបណ្តាលមកពីអត់ទឹក និងការ៉េមរលាយដោយកម្តៅ<br><br>៤.សិស្សកត់សំណួរចូលក្នុងសៀវភៅរួចគិត ពិភាក្សាក្រុមឆ្លើយដោយសរសេរចម្លើយលើក្តារឆ្នួន កំដៅ ពន្លឺ អគ្គិសនី ។ល។<br>៥.សិស្សបង្ហាញពីបាតុភូតបំលែងក្នុងជីវភាពប្រចាំថ្ងៃ ៖<br>-អុសឆេះជាធ្យូងព្រោះកម្តៅ<br>-រុក្ខជាតិលូតលាស់ព្រោះពន្លឺ និងសារធាតុចិញ្ចឹម<br>-ឧបករណ៍អគ្គិសនីផ្សេងៗដូចជាឆ្នាំងអ៊ុត ឆ្នាំងដាំបាយអគ្គិសនី...។<br>-ដូច្នេះបំលែងរូបធាតុអាចកើតឡើងដោយសារកត្តា<br>ផ្សេងៗដូចជា កម្តៅ ពន្លឺ<br>អគ្គិសនី...។ល។ |
| <br><br>-គ្រូឱ្យសិស្សឆ្លើយសំណួរ<br>ខាងក្រោម ចូរឱ្យឧទាហរណ៍មួយនៃ | ជំហានទី៤ (១០នាទី)<br>**ពង្រឹងចំណេះដឹង**<br>-ឧទាហរណ៍បំលែងរូបធាតុក្នុងជីវភាពប្រចាំថ្ងៃ។ | <br><br>-សិស្សគិត រួចឆ្លើយ |

| | | |
|---|---|---|
| បំលែងរូបធាតុ ៖<br>១.កើតឡើងដោយសារកម្តៅ<br>២.កើតឡើងដោយសារពន្លឺ<br>៣.កើតឡើងដោយសារអគ្គិសនី | | <br>១.កម្តៅធ្វើឱ្យទឹកពុះក្លាយជាចំហាយ<br>២.ពន្លឺធ្វើឱ្យថ្នាំពេទ្យខូចគុណភាព<br>៣.អគ្គិសនីអាចធ្វើឱ្យមានអគ្គីភ័យ |
| -គ្រូសរសេរសំណួរឱ្យសិស្សធ្វើកិច្ចការផ្ទះ ។<br>ចូរពិពណ៌នាបំលែងរូបធាតុឱ្យបានបីដែលកើតមានក្នុងជីវភាពប្រចាំថ្ងៃ និងប្រាប់ពីកត្តាដែលនាំឱ្យមានបំលែងរូបធាតុទាំងនោះ។ | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ** | -សិស្សកត់ត្រាសំណួរដើម្បីយកទៅធ្វើនៅផ្ទះ |

1. សង្ខេប

រូបខាងក្រោមនេះ បង្ហាញពីបំលែងដែលអាចកើតមានក្នុងពេលធ្វើពិសោធន៍ ។



បំលែងដែលកើតមានជិតៗនៅក្នុងជីវភាពប្រចាំថ្ងៃ ។




នៅជុំវិញខ្លួនយើង តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យមានបំលាស់ប្តូរភាពរូប ?

124

សៀវភៅយោងៈ VVOB ផ្នែកទី២ រូបគំនូតុក្កតាគំនិតទី៧១ "អង្គធាតុរាវ"



## **ផែនការបង្រៀន** ( C732 )

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៧
- ជំពូកទី៣ ៖ ខ្យល់
- មេរៀនទី២ ៖ ធាតុកង្វក់ខ្យល់
- រយៈពេល ៖០៦ម៉ោងសិក្សា

### I. វត្ថុបំណង :

- ពណ៌នាពីឈ្មោះធាតុពុលក្នុងខ្យល់
- ពណ៌នាពីប្រភពធាតុពុល និងឥទ្ធិពលវា
- មានស្មារតីថែរក្សាបរិស្ថាន
- ពណ៌នាពីផលផ្ទះកញ្ចក់ ។

### II-ផែនកាបង្រៀន

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល ០៦ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន**

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. កង្វក់ខ្យល់ | 142 |
| 1 | 2. ធាតុពុលក្នុងខ្យល់ និងប្រភព | 143 |
| 1 | 3. ឥទ្ធិពលមនុស្សទៅលើបរិស្ថាន<br>3.1. កំណើនកម្ដៅនៅលើផែនដី<br>3.2. ភ្លៀងអាស៊ីត | 144-145 |
| 1 | 3.3. ការស្តើងស្រទាប់អូសូន<br>3.4. ការសម្អាតខ្យល់ | 145-146 |
| 1 | 4. ផលផ្ទះកញ្ចក់ | 146-147 |
| 1 | សង្ខបមេរៀន និងសំណួរ | 148-149 |

សៀវភៅយោង ៖ ស.ស. / STEPSAM3:

### III.ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីឱ្យសិស្សអាចពន្យល់បានពីឈ្មោះឧស្ម័នពុលក្នុងខ្យល់ និងឥទ្ធិពលនៃឧស្ម័នពុលព្រមទាំងមានស្មារតីការពារថែរក្សាបរិស្ថាន។

## IV. ខ្លឹមសារពិបាក ៖

- ក្នុងមេរៀននេះ សិស្សជួបការលំបាកដូចជា ធាតុកង្វក់ខ្យល់ ធាតុពុល ឧស្ម័នផ្ទះកញ្ចក់ និងCFCs
- ក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧របស់ STEPSAM3 មានខ្លឹមសារបន្ថែម**ច្រើន**ដែលជាខ្លឹមសារសម្រាប់គ្រូមិនមែនជាខ្លឹមសារបង្រៀនទេ(គ្រូអាចមើលសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧របស់ STEPSAM3 ទំព័រទី88-89បន្ថែម)
- សិស្សមិនទាន់រៀននិមិត្តសញ្ញាគីមី ដូចជា SOx NOx COx CFC ។ល។ ពីមុនមកដូច្នេះសិស្សអាចពិបាកយល់

## V. ពិសោធន៍ និងសម្មភាពបន្ថែម ៖

- គ្រូត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំមុនបង្រៀន និងបើសិនជាមានគ្រូដែលមានបទពិសោធន៍ច្រើន ឬប្រធានក្រុមបច្ចេកទេសជួយជាការល្អ។
- មុនដំបូង គ្រូអាចជ្រើសរើសសកម្មភាពតែមួយដើម្បីអនុវត្តក្នុងមេរៀននេះតាមសៀវភៅយោងដូចជា ៖

  ១. សៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី142 ដល់ទំព័រទី143

  ២. សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧របស់ STEPSAM3 ទំព័រទី86 ដល់ទំព័រទី103

សៀវភៅយោង VSO ទំព័រទី66 ដល់ទំព័រទី67 ការបំពុលខ្យល់(ល្បែងសិក្សា)

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| ប័ណ្ណពាក្យ | ២ម៉ោង | ២០នាទី | ស្រួល | សិស្សចូលរួម |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមានមធ្យោបាយអនុវត្ត នោះនឹងទទួលមានលទ្ធផលសិក្សាល្អ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៧
- ជំពូកទី៣ ៖ ខ្យល់
- មេរៀនទី២ ៖ ធាតុកង្វក់ខ្យល់ (ត)
- ម៉ោងទី ៖ ១
- ប្រធានបទ ៖ **ធាតុពុលក្នុងខ្យល់ និងប្រភព**
- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

## I. វត្ថុបំណង ៖

- ចំណេះដឹង : ពណ៌នាពីឈ្មោះឧស្ម័នពុលក្នុងខ្យល់តាមរយៈការសង្កេត និងសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ
- បំណិន : កំណត់ពីឥទ្ធិពលនៃឧស្ម័នពុលនៅក្នុងខ្យល់តាមរយៈការពិភាក្សាក្រុមបានត្រឹមត្រូវ
- ឥរិយាបថ : សិស្សចូលរួមការពារថែរក្សាបរិស្ថាន និងមានបម្រុងប្រយ័ត្នចំពោះឧស្ម័នពុលក្នុងខ្យល់។

## II. សម្ភារបង្រៀន និងរៀន ៖

**- សៀវភៅយោង ៖**

+ សៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី142 ដល់ទំព័រទី143

+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៧របស់ STEPSAM3 ទំព័រទី91 ដល់ទំព័រទី92 ។

**- សម្ភារពិសោធ ៖**

+ ចានទម្រ ដង្កៀបចាប់ សំឡី ទៀន ឈើគូស ។

*** កំណត់សម្គាល់ ៖**

+ គ្រូអាចប្រើសម្ភារៈផ្សេងៗតាមការគិតឃើញបន្ថែម ឬប្តូរថ្មី

+ វិធីបង្រៀន និងរៀនតាមបែបរិះរក (IBL)។

## III. សកម្មភាពបង្រៀន និងរៀន :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ត្រួតពិនិត្យ<br>- អនាម័យ<br>-សណ្ដាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួល ឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -បំផុសសំណួរដូចជា ៖<br><br>១.តើខ្យល់មានសារៈសំខាន់ដូចម្ដេចខ្លះ?<br><br>២.តើខ្យល់អាចរងនូវកង្វក់ឬទេ?<br>៣.តើកង្វក់ខ្យល់មានប្រភពមកពីណាខ្លះ?<br>-បន្ទាប់មកគ្រូធ្វើសេចក្ដីភ្ជាប់មេរៀន ៖ ដូច្នេះកង្វក់ខ្យល់បង្កឱ្យមានសារធាតុពុលផ្សេងៗក្នុងខ្យល់។ថ្ងៃនេះ យើងនឹងសិក្សាពីសារធាតុពុលក្នុងខ្យល់ទាំងនោះ និងប្រភពរបស់វា។ | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br><br>-សារៈសំខាន់របស់ខ្យល់<br><br>-ប្រភពកង្វក់ខ្យល់ | -ពិភាក្សាគ្នាជាដៃគូ (ប្រើក្ដារឆ្នួន និងអាចគូររូបភាពជាចម្លើយ)<br>-គិត ហើយឆ្លើយ<br>១.ខ្យល់មានសារៈសំខាន់សម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ (ដកដង្ហើម) និងរុក្ខជាតិ(រស្មីសំយោគ)<br>២.ខ្យល់អាចរងនូវកង្វក់<br>៣.ប្រភពកង្វក់ខ្យល់មានដូចជា ផ្សែងម៉ូតូ ឡាន រោងចក្រ...។ |
| -គ្រូដាក់សំណួរបំផុស ៖<br>តើកង្វក់ខ្យល់បង្កឡើងដោយសារធាតុអ្វីខ្លះ?<br>មានប្រភពមកពីណាខ្លះ?<br>អាចបណ្ដាលឱ្យមានបញ្ហាអ្វីខ្លះ? | ជំហានទី៣ (៣០នាទី)<br>**មេរៀនថ្មី**<br>**ធាតុពុលក្នុងខ្យល់ និងប្រភព**<br>-សារធាតុបង្កឱ្យកង្វក់ខ្យល់មានដូចជា ស្ពាន់ធ័រឌីអុកស៊ីត($SO_2$) កាបូនម៉ូណូអុកស៊ីត(CO) សមាសធាតុសំណ អាសូតអុកស៊ីត(NO) និង | -ពិភាក្សាក្រុម ឬដៃគូ (ប្រើក្ដារឆ្នួន)<br>(អាចគូររូបភាពជាចម្លើយ)-សារធាតុបង្កឱ្យកង្វក់ខ្យល់មានដូចជា ស្ពាន់ធ័រឌីអុកស៊ីត($SO_4$) |

| | | |
|---|---|---|
| -បន្ទាប់មកឱ្យសិស្សគិតជាបុគ្គល ឬពិភាក្សាតាមក្រុមដោយប្រើសៀវភៅសិក្សាគោលថ្នាក់ទី៧ ទំព័រទី143។<br><br>-ឱ្យសិស្សពិសោធវត្តមានម្រែងភ្លើងដែលកើតពីចំហេះទៀននៅក្នុងខ្យល់ដែលជាឧទាហរណ៍មួយក្នុងចំណោមធាតុពុលជាច្រើនក្នុងខ្យល់តាមក្រុម | ឧស្ម័នក្លរ៉ូភ្លុយអរ៉ូកាបូន(CFCs)<br><br>-មានប្រភពមកពីចំហេះធ្យូងថ្ម ប្រេងឥន្ធនៈ បំពង់បាញ់ថ្នាំសម្លាប់សត្វល្អិត ឬទឹកអប់មួយចំនួន ...<br><br>-ឧស្ម័នទាំងនោះបណ្តាលឱ្យមានភ្លៀងអាស៊ីត ធ្វើឱ្យស្រទាប់អូសូនស្តើង ឬធ្លុះធ្លាយ និងបណ្តាលមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ខួរក្បាលក្មេង។<br>**ប្លង់ពិសោធ**<br> | កាបូនម៉ូណូអុកស៊ីត(CO) សមាសធាតុសំណ អាសូតអុកស៊ីត(NO) និងឧស្ម័នក្លរ៉ូភ្លុយអរ៉ូកាបូន(CFCs) -មានប្រភពមកពីចំហេះធ្យូងថ្ម ប្រេងឥន្ធនៈ បំពង់បាញ់ថ្នាំសម្លាប់សត្វល្អិត ឬទឹកអប់មួយចំនួន ...<br>-ឧស្ម័នទាំងនោះបណ្តាលឱ្យមានភ្លៀងអាស៊ីត ធ្វើឱ្យស្រទាប់អូសូនស្តើង ឬធ្លុះធ្លាយ និងបណ្តាលមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ខួរក្បាលក្មេង<br>-សង្កេត និងកត់សម្គាល់ |

<table>
<tr>
<td>-គ្រូឱ្យសិស្សគិតជាបុគ្គល ដើម្បីឆ្លើយសំណួរផ្គូផ្គងឧស្ម័ននីមួយៗខាងក្រោម ទៅនឹងផលប៉ះពាល់របស់វា ៖</td>
<td>ជំហានទី៤ (១០នាទី)<br>ពង្រឹងចំណេះដឹង
<table>
<tr><td>១.ស្ពាន់ធ័រអុកស៊ីត (SOx)</td><td>ក.បង្កើនកម្ដៅផែនដី (ឧស្ម័នផ្ទះកញ្ចក់)</td></tr>
<tr><td>២.អាសូតអុកស៊ីត (NOx)</td><td>ខ.បង្កឱ្យកើតជំងឺសួត និងភ្លៀងអាស៊ីត</td></tr>
<tr><td>៣.សំណតេត្រា អេទីល ($Pb(C_2H_5)_4$)</td><td>គ.មានផ្ទុកលោហៈពុល និងបង្កឱ្យប៉ះពាល់ដល់ខួរក្បាល</td></tr>
<tr><td>៤.កាបូនម៉ូណូអុកស៊ីត (CO)</td><td>ឃ.ធ្វើឱ្យស្តើងស្រទាប់អូសូន</td></tr>
<tr><td>៥.កាបូនឌីអុកស៊ីត ($CO_2$)</td><td>ង.បង្កឱ្យគ្រោះថ្នាក់ដល់សុខភាពដូចជាបញ្ហាជំងឺបេះដូង និងសួត</td></tr>
<tr><td>៦.ក្លរ៉ូភ្លុយអរ៉ូកាបូន (CFCs)</td><td>ច.ជាឧស្ម័នគ្មានពណ៌ គ្មានក្លិន និងគ្មានរសជាតិ ប៉ុន្តែពុលខ្លាំង</td></tr>
<tr><td>៧.មេតាន ($CH_4$)</td><td></td></tr>
</table>
សៀវភៅយោង៖ STEPSAM3</td>
<td>-សិស្សគិតជាបុគ្គល និងបង្ហាញចម្លើយលើក្ដារឆ្នួន ៖<br>១. ខ និង ង<br>២. ខ និង ង<br>៣. គ<br>៤. ច<br>៥. ក<br>៦. ឃ និង ក<br>៧. ក</td>
</tr>
<tr>
<td>-គ្រូប្រាប់ឱ្យសិស្សធ្វើសំណួរ និងលំហាត់បញ្ចប់ជំពូក៣ សំណួរ I និង II។</td>
<td>ជំហានទី៥ (៣នាទី)<br>កិច្ចការផ្ទះ<br>-សំណួរ និងលំហាត់បញ្ចប់ ជំពូក៣ សំណួរ I និង II ទំព័រទី 149</td>
<td>-សិស្សកត់ត្រា និងត្រៀមលក្ខណៈធ្វើលំហាត់នៅផ្ទះ ។</td>
</tr>
</table>

# **ផែនការបង្រៀន** (C812)

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៨
- ជំពូកទី១ ៖ ទ្រឹស្តីម៉ូលេគុល-អាតូម
- មេរៀនទី២ ៖ និមិត្តសញ្ញា រូបមន្តគីមី និងប្រតិកម្មគីមី
- រយៈពេល ៖ ០៦ម៉ោងសិក្សា

## I. វត្ថុបំណង ៖

- ពណ៌នាពីនិមិត្តសញ្ញា និងរូបមន្តគីមី
- សរសេរនិមិត្តសញ្ញានៃធាតុគីមី និងរូបមន្តគីមីនៃអង្គធាតុដែលបានសិក្សា
- ពណ៌នាពីបំលែងគីមី ឬប្រតិកម្មគីមី ។

## II-ផែនកាបង្រៀន ៖

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល ៦ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន** (សៀវភៅយោង ៖ ស.ស. / STEPSAM3)

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. និមិត្តសញ្ញាគីមី | 108- 110 |
| 1 | 2. រូបមន្តគីមី<br>3. វ៉ាឡង់គីមី<br>3.1 សង្កេត<br>3.2 និយមន័យ<br>3.3 វ៉ាឡង់នៃរ៉ាឌីកាល់<br>3.4 ការតាក់តែងរូបមន្ត | 110 - 112 |
| 1 | 3. 5.ម៉ាសម៉ូលេគុល | 112 |
| 1 | 4. ប្រតិកម្មគីមី<br>4.1 បាតុភូតរូប ឬបំលែងរូប<br>4.2 បាតុភូតគីមី ឬបំលែងគីមី | 113 |
| 1 | 5. ច្បាប់រក្សាម៉ាស | 114 |
| 1 | សង្ខបមេរៀន<br>សំណួរ និងលំហាត់ | 114-115 |

## III.ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីឱ្យសិស្ស ៖

- ពណ៌នា និងសរសេនិមិត្តសញ្ញាគីមី និងរូបមន្តគីមី
- ពន្យល់ពីសារៈសំខាន់នៃវ៉ាឡង់គីមី ចំពោះការសរសេររូបមន្តគីមី

- ពន្យល់ពីការសរសេរ និងថ្លឹងសមីការគីមី
- គណនាម៉ាសម៉ូលេគុលនៃសមាសធាតុគីមី
- ពន្យល់ពីលំនាំប្រតិកម្មគីមី និងសរសេរសមីការតាងប្រតិកម្ម
- ពន្យល់ និងអនុវត្តច្បាប់រក្សាម៉ាសសម្រាប់បប្រតិកម្មគីមី

**IV.ខ្លឹមសារពិបាក ៖**

- ក្នុងមេរៀននេះ សិស្សអាចជួបការលំបាកដូចជា
  1. ការប្រើប្រាស់អក្សរឡាតាំង លើការហៅឈ្មោះនិមិត្តសញ្ញាគីមី
  2. ការរៀនពីវ៉ាឡង់គីមី ព្រោះសិស្សមិនទាន់រៀនពីតារាងខួបនៃធាតុគីមី (រៀននៅថ្នាក់ទី៩ ជំពូក១ មេរៀនទី១ និងទី២)

**V. ពិសោធន៍ និងសម្មភាពបន្ថែម ៖**

- គ្រូត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំ មុនបង្រៀន និងបើសិនជាមានគ្រូដែលមានបទពិសោធន៍ច្រើន ឬប្រធានក្រុមបច្ចេកទេសជួយជាការល្អ។
- មុនដំបូង គ្រូអាចជ្រើសរើសសកម្មភាពតែមួយដើម្បីអនុវត្តក្នុងមេរៀននេះតាមសៀវភៅយោងដូចជា ៖

១. សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៨របស់ STEPSAM3

1. គំរូតារាងសម្រាប់បំពេញរូបមន្តគីមី

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| តារាងរូបមន្តគីមី | ២០នាទី | ១៥-២៥ នាទី | ស្រួល | សិស្សចូលរួម |

2. តារាងឈ្មោះដើមជាភាសាឡាតាំង

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| តារាងឈ្មោះនិមិត្តសញ្ញាធាតុគីមីចំនួន២០ធាតុ | ៣០នាទី | ២០ នាទី | ស្រួល | សិស្សចូលរួម |

3. សំណួរខ្លី ចម្លើយ និងរបៀបដាក់ពិន្ទុ សម្រាប់មេរៀននិមិត្តសញ្ញាគីមី រូបមន្តគីមី និងប្រតិកម្មគីមី

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| ខ្លឹមសារសំណួរ និងចម្លើយ | ១នាទី | ៥០ នាទី | ស្រួល | សិស្សចូលរួម |

សកម្មភាពទ្រឹស្តីនេះមានគោលបំណងពង្រឹងការរៀន ប៉ុន្តែបើសិនជាគ្រូមានពេលវេលា និងចង់អនុវត្តពិសោធន៍អាចធ្វើបាន។

២. ស.ស VSO: 1.ល្បែង Bingo គីមី

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| ក្រដាស/ក្រដាសការតុង ឬ ក្តារឆ្នួន | ០-៣០ នាទី (បើប្រើក្តារឆ្នួនគ្មានពេលវេលារៀបចំទេ) | ១០-២០ នាទី | ស្រួល | សិស្សចូលរួម |

- គ្រូអាចត្រៀមរៀបចំកាត Bingo ជាមុនសិន ឬអាចណែនាំឱ្យសិស្សប្រើប្រាស់និងសរសេរលើក្តារឆ្នួនរបស់ពួកគេ

2. ប្រាប់ពីវ៉ាឡង់របស់ធាតុគីមីក្នុងរូបមន្តគីមី

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| ក្រដាស/ក្រដាសកាតុង | ២០-៣០ នាទី | ២0 នាទី | ស្រួល | សិស្សចូលរួម |

. ក្នុងសៀវភៅ VSO ហៅថាកម្មភាពខាងលើទាក់ទងមេរៀនទី៣ ដែលជាកំហុសមួយ គួតែហៅថាសកម្មភាពទាក់ទងជាមួយមេរៀនទី២វិញ ។

. ក្នុងសៀវភៅសិក្សាគោលវ៉ាឡង់ទាំងអស់មានលេខ **វិជ្ជមាន** សកម្មភាពខាងលើនៅសៀវភៅ VSO ប្រើប្រាស់វ៉ាឡង់មានលេខ **វិជ្ជមាន និង អវិជ្ជមាន** ដើម្បីឱ្យសិស្សរៀនស្រួល ។

3. សមីការគីមី និងគំរូអាតូម

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| គំរបដប (ច្រើន) | ពី ៣០ នាទីឡើងទៅ | ៣០ នាទី | ស្រួល / មធ្យម | សិស្សចូលរួម |

សកម្មភាពនេះធ្វើឱ្យសិស្សសប្បាយ ប៉ុន្តែគ្រូត្រូវប្រើពេលវេលាច្រើនក្នុងការរៀបចំ ដូចនេះដើម្បីសំចៃពេលវេលាគ្រូត្រូវប្រាប់សិស្សមួយឬពីរអាទិត្យមុននឹងបង្រៀនមេរៀននេះ ដើម្បីឱ្យពួកគេប្រមូលគម្របដបទឹកបរិសុទ្ធទុកឱ្យបានច្រើន។

-សៀវភៅ VSO ណែនាំអំពី (គីមីវិទ្យាថ្នាក់ទី៨ ជំពូកទី១ មេរៀនទី២ នៅសៀវភៅVSO ទំព័រទី161 - 166) :

| **សម្ភារៈ៖ធម្មតា / ពិសេស** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| ផ្សេងៗ ត្រូវពិនិត្រមើល ក្នុងសៀវភៅណែនាំគ្រូ | ១០នាទី ឡើងទៅ | ៣០-៤០ នាទី | មធ្យម / ពិបាក | គ្រូបង្ហាញ (សិស្សអាចចូលរួម សកម្មភាពមួយចំនួនបាន) |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមាន មធ្យោបាយអនុវត្តបាន នោះសិស្សនឹងទទួលបានលទ្ធផលសិក្សាល្អ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមី
- ថ្នាក់ទី ៖ ៨
- ជំពូកទី១ ៖ ទ្រឹស្ដីម៉ូលេគុល-អាតូម
- មេរៀនទី២ ៖ និមិត្តសញ្ញា រូបមន្តគីមី និងប្រតិកម្មគីមី
- ម៉ោងទី ៖ ១
- ប្រធានបទ ៖ **និមិត្តសញ្ញាគីមី**
- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

## I. វត្ថុបំណង ៖

- ចំណេះដឹង ៖ ពណ៌នាពីនិមិត្តសញ្ញាគីមី និងឈ្មោះធាតុគីមីសំខាន់ៗចំនួន២០ដំបូងតាមរយៈការបង្ហាញកាត (ប័ណ្ណពាក្យ) និងសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ
- បំណិន ៖ សរសេរនិមិត្តសញ្ញាគីមី និងឈ្មោះធាតុគីមីសំខាន់ៗចំនួន២០ដំបូងតាមរយៈការពិភាក្សាក្រុម ឬដៃគូរបស់សិស្សលើសំណួររបស់គ្រូបានត្រឹមត្រូវ
- ឥរិយាបថ ៖ បង្កើនចំណូលចិត្តសិស្សស្វែងយល់ពីនិមិត្តសញ្ញាធាតុគីមីដែលមានក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងក្នុងធម្មជាតិ ។

## II. សម្ភារបង្រៀន និងរៀន ៖

**- សៀវភៅយោង ៖**

+ សៀវភៅសិក្សាគោលថ្នាក់ទី៨ទំព័រទី 108 ដល់ទំព័រទី 110
+ សៀវភៅណែនាំគ្រូថ្នាក់ទី៨របស់ VSO ទំព័រទី 66 ដល់ទំព័រទី 68
+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៨របស់ STEPSAM3 ទំព័រទី19 ដល់ទំព័រទី21 ។

**- សម្ភារឧបទេស ៖**

+ ប័ណ្ណពាក្យ ឈ្មោះនិងនិមិត្តសញ្ញាគីមីនៃធាតុគីមី
(ម្ខាងសរសេរនិមិត្តសញ្ញា និងម្ខាងទៀតសរសេរឈ្មោះធាតុគីមី)
+ តារាងនិមិត្តសញ្ញាធាតុគីមីខ្លះៗ(តារាងទី1 សៀវភៅសិក្សាគោលទំព័រទី109)
+ វិធីរៀនដោយការចូលរួម និងការប្រើប្រាស់សំណួរបើក ។

## III. សកម្មភាពបង្រៀន និងរៀន ៖

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្ដាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្រប សម្រួល ឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -បំផុសសំណួរ និងប្រាប់ឱ្យសិស្សសរសេរចម្លើយលើក្ដារឆ្នួន ៖<br><br>១.ដូចម្ដេចដែលហៅថាអាតូម?<br><br>២.តើអាតូមនៃធាតុគីមីដូចគ្នា និងធាតុគីមីផ្សេងគ្នាខុសគ្នាយ៉ាងដូចម្ដេច ?<br><br>-គ្រូពោលះធាតុគីមីមានច្រើនប្រភេទ។<br>ដើម្បីងាយស្រួលសិក្សាគេតាងធាតុគីមីនីមួយៗដោយនិមិត្តសញ្ញាផ្សេងៗគ្នា។<br>ថ្ងៃនេះយើងនឹងសិក្សាអំពីនិមិត្តសញ្ញាគីមី។ | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br>- បញ្ញាតិស្ដីពីអាតូម | -ពិភាក្សាគ្នាជាដៃគូ និងឆ្លើយ (សិស្សប្រើក្ដារឆ្នួន)<br>(សិស្សអាចគូររូបភាពជាចម្លើយ)<br>១.អាតូមគឺជាផង់តូចបំផុតដែលមិនអាចបំបែកជាសារធាតុងាយផ្សេងទៀតបាន ។<br><br>-អាតូមនៃធាតុគីមីដូចគ្នាមានលក្ខណៈ និងម៉ាសដូចគ្នា ។<br>-អាតូមនៃធាតុគីមីផ្សេងគ្នាមានលក្ខណៈ និងម៉ាសខុសគ្នា ។ |
| | ជំហានទី៣ (៣០នាទី)<br>**មេរៀនថ្មី**<br>**និមិត្តសញ្ញាគីមី** | |

| | | |
|---|---|---|
| -បែងចែកសិស្សជាដៃគូ/ក្រុមតូចៗ តាមការចាប់ឆ្នោត<br>-បំផុសសំណួរ និងឱ្យសិស្សសរសេរចម្លើយលើក្ដារឆ្នួន :<br>-តើអ្នកគីមីវិទ្យាប្រើអ្វីដើម្បីតាងអាតូមនៃធាតុគីមី ?<br>-បន្ទាប់មកឱ្យសិស្សអានសៀវភៅសិក្សាគោលថ្នាក់ទី៨ទំព័រ109-110 ពិភាក្សាជាមួយដៃគូរ រួចឆ្លើយសំណួរខាងលើ ។<br>-បង្ហាញប័ណ្ណពាក្យនៃធាតុគីមីដូចខាងក្រោម ឬអាចយកសម្ភារៈជាក់ស្ដែងក៏បាន ៖<br>Fe Cu Al Zn<br>-រួចផ្ដល់សំណួរ និងឱ្យសិស្សសរសេរចម្លើយលើក្ដារឆ្នួនរៀងៗខ្លួន<br>-តើប្អូនៗស្គាល់ប័ណ្ណពាក្យទាំងនេះទេ?វាតាងឱ្យអ្វី?<br>-គ្រូលើកប័ណ្ណពាក្យម្ដងមួយរួចសួរតើប័ណ្ណពាក្យនេះជានិមិត្តសញ្ញានៃធាតុគីមីអ្វី ?<br>១. F<br>២. K<br>៣. Pb<br>៤. H | 1.និមិត្តសញ្ញាគីមី<br>-ប័ណ្ណពាក្យនីមួយៗតាងឱ្យ ៖<br>.Fe : (Iron)ដែក<br>.Cu : (Copper)ទង់ដែង<br>.Al : (Aluminium)អាលុយមីញ៉ូម<br>.Zn : (Zinc)ស័ង្កសី<br>ប័ណ្ណពាក្យនីមួយៗ<br>-F **ភ្លុយអរ(Fluorine)**<br>-K **ប៉ូតាស្យូម(Potassium)**<br>-Pb **សំណ**<br>**(ឡាតាំង Plumbum / អង់គ្លេសLead)**<br>-H **អ៊ីដ្រូសែន(Hydrogen)** | -អង្គុយតាមក្រុម/ដៃគូ<br>-អ្នកគីមីវិទ្យាប្រើនិមិត្តសញ្ញាគីមីដើម្បីតាងអាតូមនៃធាតុគីមី<br>-អានខ្លឹមសារក្នុងសៀវភៅសិក្សាគោលថ្នាក់ទី៨ទំព័រ109-110 និងសរសេរចម្លើយលើក្ដារឆ្នួនពីអាតូមនៃធាតុគីមី ។<br>-សង្កេត រួចសរសេរចម្លើយរៀងៗខ្លួនលើក្ដារឆ្នួន<br>-ស្គាល់<br>-វាតាងឱ្យនិមិត្តសញ្ញាគីមី<br>-សង្កេត រួចសរសេរចម្លើយរៀងៗខ្លួនលើក្ដារឆ្នួន<br>១.ធាតុ**ភ្លុយអរ**<br>២.ធាតុ**ប៉ូតាស្យូម** |

<table>
<tr>
<td></td>
<td></td>
<td>៣.ធាតុសំណ<br><br>៤.ធាតុអ៊ីដ្រូសែន</td>
</tr>
<tr>
<td>-បន្តសួរសំណួរឱ្យសិស្សឆ្លើយ<br><br>១.អ្វីទៅជានិមិត្តសញ្ញាគីមី ?<br><br>២.តើគេកំណត់និមិត្តសញ្ញាគីមីយ៉ាងដូចម្ដេច?ចូរឱ្យឧទាហរណ៍ចំនួនពីរ ។</td>
<td>និមិត្តសញ្ញាគីមីជាច្រើនជាអក្សរបំព្រួញឈ្មោះធាតុជាភាសាអង់គ្លេស ។<br>ឧទាហរណ៍ :<br>-ស្ពាន់ធ័រឈ្មោះជាភាសាអង់គ្លេស Sulphur តាងដោយនិមិត្តសញ្ញា S<br>-អ៊ីដ្រូសែនឈ្មោះជាភាសាអង់គ្លេស Hydrogenតាងដោយនិមិត្តសញ្ញា H</td>
<td>-សរសេរចម្លើយលើក្ដារឆ្នួន<br><br>១.តាងឱ្យអាតូមនៃធាតុគីមី<br><br>២.ដោយអក្សរមួយតួ ឬពីរតួ ដែលតួទីមួយខាងដើមសរសេរអក្សរធំហើយតួទីពីរបន្ទាប់សរសេរអក្សរតូចនៃពាក្យឡាតាំង ឬអន្តរជាតិដទៃទៀត ។<br>ឧទាហរណ៍ទី១ :<br>-H តាងធាតុអ៊ីដ្រូសែន<br>-He តាងធាតុអេល្យូម<br>ឧទាហរណ៍ទី២ :<br>-C តាងធាតុកាបូន<br>-Ca តាងធាតុកាល់ស្យូម</td>
</tr>
<tr>
<td>-ហេតុអ្វីចាំបាច់ត្រូវមាននិមិត្តសញ្ញាគីមី?</td>
<td></td>
<td>-ងាយសម្គាល់ធាតុនីមួយៗឱ្យច្បាស់</td>
</tr>
<tr>
<td>-ឱ្យសិស្សសង្កេត និងអានតារាងទី1 ក្នុងសៀវភៅសិក្សាគោលទំព័រទី109</td>
<td>តារាងទី1:និមិត្តសញ្ញាធាតុគីមីខ្លះ:
<table>
<tr><th>ឈ្មោះធាតុគីមី</th><th>និមិត្តសញ្ញា</th><th>ម៉ាសអាតូម</th></tr>
<tr><td>អ៊ីដ្រូសែន</td><td>H</td><td></td></tr>
<tr><td>អេល្យូម</td><td>He</td><td></td></tr>
<tr><td>អាលុយមីញ៉ូម</td><td>Al</td><td></td></tr>
<tr><td>ប៊ រ</td><td>B</td><td></td></tr>
<tr><td>កាបូន</td><td>C</td><td></td></tr>
</table></td>
<td>-សង្កេតរួចអាន</td>
</tr>
</table>

<table>
<tr>
<td>-ពន្យល់ណែនាំបន្ថែមពីអត្ថន័យក្នុងតារាង</td>
<td>
<table>
<tr><td>កូបាល់</td><td>Co</td><td></td></tr>
<tr><td>ទង់ដែង</td><td>Cu</td><td></td></tr>
<tr><td>ដែក</td><td>Fe</td><td></td></tr>
<tr><td>ភ្លុយអរ</td><td>F</td><td></td></tr>
<tr><td>ប៉ូតាស្យូម</td><td>K</td><td></td></tr>
<tr><td>អាសូត</td><td>N</td><td></td></tr>
<tr><td>សូដ្យូម</td><td>Na</td><td></td></tr>
<tr><td>ម៉ាញេស្យូម</td><td>Mg</td><td></td></tr>
<tr><td>សំណ</td><td>Pb</td><td></td></tr>
<tr><td>អុកស៊ីសែន</td><td>O</td><td></td></tr>
<tr><td>ស្ពាន់ធ័រ</td><td>S</td><td></td></tr>
<tr><td>បារត</td><td>Hg</td><td></td></tr>
<tr><td>មាស</td><td>Au</td><td></td></tr>
<tr><td>ប្រាក់</td><td>Ag</td><td></td></tr>
<tr><td>ប្លាទីន</td><td>Pt</td><td></td></tr>
</table>
</td>
<td>-សិស្សស្តាប់ដោយយកចិត្តទុកដាក់</td>
</tr>
<tr>
<td>-គ្រូលើកប័ណ្ណពាក្យឈ្មោះធាតុគីមីបង្ហាញឱ្យសិស្សអាន រួចប្រាប់ពីនិមិត្តសញ្ញាគីមីនៃឈ្មោះធាតុគីមីនិមួយៗ<br><br>អេល្យូម<br>សូដ្យូម<br>កាបូន<br>ស្ពាន់ធ័រ<br><br>(សំណួរបន្ថែម៖តើយើងធ្លាប់ដឹងធាតុគីមីនីមួយៗនៅកន្លែងណាខ្លះ?<br>He Na C S)</td>
<td>ជំហានទី៤ (១០នាទី)<br>ពង្រឹងចំណេះដឹង<br><br>អេល្យូម → He<br>សូដ្យូម → Na<br>កាបូន → C<br>ស្ពាន់ធ័រ → S</td>
<td>-ធាតុនិមួយៗគឺ :<br><br>He<br>Na<br>C<br>S<br><br>(He: ក្នុងប៉េាង Na: អំបិល (NaCl) ប៊ីចេង (MSG) C: ធ្យូង ខ្មៅដៃ ។ល។<br>S: កាំជ្រួច)</td>
</tr>
</table>

| | | |
|---|---|---|
| -ចូរប្អូនៗអានតារាងទី1នៃនិមិត្តសញ្ញាគីមី ។<br>-ចូរប្អូនៗសរសេរនិមិត្តសញ្ញានៃធាតុគីមីខាងក្រោម ៖ កូបាល់ ទង់ដែង ដែក ភ្លុយអរ សំណ<br>មាស និងប្លាទីន | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ**<br>កូបាល់ ទង់ដែង ដែក ភ្លុយអរ សំណ មាស និងប្លាទីន | -សិស្សស្តាប់<br>-សិស្សកត់ត្រា |

*សម្គាល់៖ នៅក្នុងជំហានទី៤ គ្រូអាចឱ្យសិស្សអនុវត្តល្បែងសិក្សារបស់VSO(Bingo Game) ទំព័រទី66-68។*

## ផែនការបង្រៀន (C822)

- មុខវិជ្ជា ៖ គីមី
- ថ្នាក់ទី ៖ ៨
- ជំពូកទី២ ៖ ល្បាយ និងវិធីញែកល្បាយ
- រយៈពេល ៖ ០៦ម៉ោងសិក្សា

### I. វត្ថុបំណង ៖

- កំណត់និយមន័យល្បាយ
- ពណ៌នាលក្ខណៈ និងធាតុបង្កល្បាយ
- ញែកសម្គាល់ ល្បាយស្មើសាច់ និងល្បាយមិនស្មើសាច់ ។

### II-ផែនកាបង្រៀន ៖

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល ៦ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន**

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. សង្កេត<br>2. វិធីញែកល្បាយ<br>2.1. ចម្រោះ | 128- 129 |
| 1 | 2.2. រំហួត | 130 |
| 1 | 2.3. កំណក្រាម | 130-131 |
| 1 | 2.4. បំណិត<br>ក. បំណិតធម្មតា | 131 |
| 1 | ខ. បំណិតប្រភាគ | 132 |
| 1 | សង្ខេបមេរៀន និងសំណួរ | 133 |

សៀវភៅយោង ៖ ស.ស. / STEPSAM3:

### III.ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីឱ្យសិស្សអាចពន្យល់បានពីវិធីផ្សេងៗដូចជា វិធីច្រោះ វិធីកំណកក្រាម រំហួត បំណិតធម្មតា និងបំណិតប្រភាគ និងដើម្បីញែកល្បាយយកអង្គធាតុរឹងសុទ្ធពីអង្គធាតុរាវក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

### IV.ខ្លឹមសារពិបាក ៖

សិស្សអាចពិបាកយល់ ឬយល់ច្រឡំចំពោះបញ្ញាតិ៖

១.ការញែកល្បាយជាសារធាតុសុទ្ធតាមវិធីរូប វិធីគីមី

២.ភាពខុសគ្នានៃសារធាតុបង្ក

៣.កម្រិតរលាយ

៤.ដង់ស៊ីតេ

៥.ចំណុចរំហើរ។ល។

## V. ពិសោធន៍ និងសម្មភាពបន្ថែម ៖

- គ្រូត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំ មុនបង្រៀន និងបើសិនជាមានគ្រូដែលមានបទពិសោធន៍ច្រើន ឬប្រធានក្រុមបច្ចេកទេសជួយជាការល្អ។
- មុនដំបូង គ្រូអាចជ្រើសរើសសកម្មភាពតែមួយដើម្បីអនុវត្តក្នុងមេរៀននេះតាមសៀវភៅយោងដូចជា ៖

សៀវភៅយោង៖ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៨របស់ STEPSAM3 ទំព័រទី62 ដល់ទំព័រទី75

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| **1. ចម្រោះ**<br>- ដីខ្សាច់<br>- អំបិល<br>- ក្រដាសច្រោះ/ ក្រដាស តម្រង | ២០នាទី | ៥ នាទី | ស្រួល | សិស្សចូលរួម |
| **2. រំហួត**<br>- ទឹកអំបិល<br>- ដីវឡាវ<br>- ក្រដាសតម្រង<br>- កែវ | ២០នាទី | ១០នាទី | ស្រួល | សិស្សចូលរួម |
| **3. កំណក្រោម**<br>- ស្ករស<br>- ទឹក<br>- កែវ<br>- ខ្មៅដៃ<br>- ចង្រៀងអាល់កុល<br>- ចង្កឹះ/ឡេវអារ<br>- ជើងទម្រ | ២០នាទី | ២ម៉ោង | ពិបាក | សិស្សចូលរួម |

| | | | | |
|---|---|---|---|---|
| **4. បំណិត**<br>- កែវបាឡុង/ផ្ទុក<br>- ទែម៉ូម៉ែត្រ<br>- ទឹកអំបិល<br>- ជើងទម្រ<br>- ចង្រ្កៀងអាល់កុល<br>- ទឹកកក | ១ម៉ោង | ២០នាទី | ពិបាក | សិស្សចូលរួម |
| **5. បំណិតប្រភាគ**<br>- បំពង់ប្រណិតប្រភាគ<br>- ទែម៉ូម៉ែត្រ<br>- ទឹក<br>- សីតករ<br>- អាល់កុល | ២០នាទី | ១០នាទី | ស្រួល | សិស្សចូលរួម |

សៀវភៅយោង៖ VVOB សៀវភៅពិសោធន៍គីមី ទំព័រទី2 ដល់ទំព័រទី3

| សម្ភារៈ ៖ ធម្មតា | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| - ខ្សាច់១ថង់<br>- ដុំគ្រួស១ថង់<br>- កញ្ច្រែងក្រឡាល្អិត<br>- មេដែក<br>- ដីស១ដើម<br>- ចានទាប១<br>- ដីវឡារ១<br>- ក្រដាសច្រោះ<br>- កូនស្លាព្រា១<br>- កែវបេស៊ែ១<br>-ដបផ្លាស្ទិច១ | ២ម៉ោង | ១ម៉ោង | ធម្មតា | សិស្សចូលរួម |

សៀវភៅយោង៖  VSO សៀវភៅពិសោធន៍គីមី ទំព័រទី168 ដល់ទំព័រទី169

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| - ស្លាបព្រាបាយ<br>- ដែកគោល<br>- ដង្កៀប<br>- មេដែក<br>- ថូ ឬដប<br>- ទៀន<br>- ឈើគូស<br>- សំលី<br>- ក្រដាស<br>-ដបផ្លាស្ទិច១ | ២ម៉ោង | ១ម៉ោង | ស្រួល | សិស្សចូលរួម |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមានមធ្យោបាយអនុវត្តបាន នោះសិស្សនឹងទទួលបានលទ្ធផលសិក្សាល្អ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៨
- ជំពូកទី២ ៖ ល្បាយ និងវិធីញែកល្បាយ
- មេរៀនទី២ ៖ ការញែកល្បាយ
- ម៉ោងទី ៖ ១
- ប្រធានបទ ៖ **វិធីញែកល្បាយដោយចម្រោះ និងរំហួត**
- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

**I. វត្ថុបំណង ៖**

- ចំណេះដឹង ៖ ពណ៌នាពីវិធីញែកល្បាយដោយវិធីច្រោះ និងរំហួតដើម្បីបានសារធាតុសុទ្ធ តាមរយៈការពិសោធ និងសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ
- បំណិន ៖ អនុវត្តវិធីច្រោះដើម្បីញែកល្បាយយកអង្គធាតុរឹងសុទ្ធពីអង្គធាតុរាវតាមរយៈការធ្វើពិសោធន៍ផ្ទាល់ជាក្រុមបានត្រឹមត្រូវ
- ឥរិយាបថ ៖ បង្កើនការចូលចិត្តសិក្សាគីមីវិទ្យាតាមរយៈការសិក្សាល្បាយ និងពិសោធន៍ញែកល្បាយដែលទាក់ទងក្នុងជីវភាពប្រចាំថ្ងៃ ។

**II. សម្ភារបង្រៀន និងរៀន ៖**

**- សៀវភៅយោង ៖**

+ សៀវភៅសិក្សាគោលថ្នាក់ទី៨ទំព័រទី128 ដល់ទំព័រទី129
+ សៀវភៅណែនាំគ្រូរបស់ VVOB ផ្នែកទី២ រូបគំនូរតុក្កតាគំនិតទី73 "ទឹកស្អាត"
+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៨របស់ STEPSAM3 ទំព័រទី64 ដល់ទំព័រទី66 ។

**- សម្ភារពិសោធន៍ ៖**

+ ជីឡាវ កែវបេស៊ែ100ml ក្រដាសតម្រង មេដែក ចង្កឹះកែវ(ឈើ ឬជ័រ) ចង្កៀងអាល់កុល
+ ទឹក អំបិល ដីខ្សាច់ ម្សៅដែក គ្រាប់សណ្តែកបាយ ស្រាស ។

*** កំណត់សម្គាល់ ៖**

+ យើងអាចរកម្សៅដែក(កម្ទេចដែក)នៅកន្លែងជាងធ្វើបង្អួច ទ្វារដែកយកពីអាចម៍រណាកាត់ដែក
+ បើគ្មានឡាវ(ជីឡាវ)អាចកាត់ដបទឹកសុទ្ធយកផ្នែកខាងមាត់ដបមក
+ ការញែកយកកម្ទេចដែកចេញពីល្បាយដោយយកមេដែកឆក់ល្បាយស្ងួត និងឆក់ដែកក្នុងល្បាយក្នុងទឹក តើមានអ្វីខុសគ្នាឬទេ?
+ បើសិនជាហួសម៉ោងសិក្សានៅជំហានទី៣ អាចប្រើប្រាស់រូបគំនូរតុក្កតាគំនិតទី73 "ទឹកស្អាត" នៅម៉ោងសិក្សាទី២ជំហានទី២
+ វិធីបង្រៀន និងរៀនតាមបែបរិះរក (IBL)

## III. សកម្មភាពបង្រៀន និងរៀន ៖

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្តាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្រប សម្រួល ឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -គ្រូបំផុសសំណួរផ្ទាល់មាត់ ឬបើអាចគូរសរសេរលើក្តារខៀនលើសំណួរ ៖<br>១.ដូចម្តេចដែលហៅថាអង្គធាតុសុទ្ធ?<br><br>២.ដូចម្តេចដែលហៅថាល្បាយ ?<br><br>៣.បើយើងចង់បានអង្គធាតុសុទ្ធមួយពីល្បាយមួយ តើប្អូនត្រូវធ្វើដូចម្តេច ? | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br><br>- អង្គធាតុសុទ្ធ<br><br>-ល្បាយ<br><br>-ញែកល្បាយ | -សិស្សស្តាប់ គិត ឆ្លើយជាបុគ្គល (សិស្សប្រើក្តារឆ្នួន)<br>១.អង្គធាតុសុទ្ធជាអង្គធាតុដែលផ្សំដោយម៉ូលេគុលតែមួយប្រភេទ ។<br>២.ល្បាយជារូបធាតុដែលបង្កឡើងដោយសារធាតុពីរ ឬច្រើនបិតនៅលាយឡំគ្នាដោយមិនរងប្រតិកម្មគីមី ។<br>(សិស្សប្រើក្តារឆ្នួនគូររូបភាព)<br><br>៣.ប្រើវិធីញែកល្បាយ ។ |
| | ជំហានទី៣ (៣០នាទី)<br>**មេរៀនថ្មី**<br>**វិធីញែកល្បាយដោយចម្រោះ និងរំហួត** | |

| | | |
|---|---|---|
| -គ្រូឱ្យសិស្សសង្កេតពីល្បាយសារធាតុមួយចំនួនដូចជា ៖<br>a.អំបិលលាយសណ្ដែកបាយ<br>b.ដីខ្សាច់+ទឹក<br>c.អំបិល+ទឹក<br>d.ស្រាស+ទឹក<br>-រួចសួរសំណួរបំផុស :<br>-តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីញែកល្បាយនិមួយៗខាងលើ ?<br><br>-គ្រូបន្តសំណួរ :<br>-តើគេអាចប្រើវិធីច្រោះបាននៅពេលណា ? | -សង្កេត<br><br><br>-វិធីញែកល្បាយមានច្រើនដូចជា: ចម្រោះ រំហួត បង្ហូត កំណក្រាម បំណិត ... ។ | -សិស្សសង្កេត រួចឆ្លើយ<br><br>- a. ប្រើវិធីរែង<br>b. ប្រើវិធីចម្រោះ<br>c. ប្រើវិធីរំហួត<br>d. ប្រើវិធីបំណិតប្រភាគ<br><br>-ពេលណាគេចង់បានអង្គធាតុរឹងសុទ្ធពីអង្គធាតុរាវ ឬអង្គធាតុរាវសុទ្ធពីអង្គធាតុរឹង ។ |
| **សំណួរគន្លឹះ :** យើងមានល្បាយដីខ្សាច់ អំបិល និងម៉ៅ្យដែក តើប្អូនអាចញែកយកអង្គធាតុសុទ្ធនិមួយៗចេញពីល្បាយនេះដោយវិធីណាខ្លះ ? | | |
| -គ្រូបង្ហាញសម្ភារៈដែលមានសម្រាប់ការពិសោធដូចជា មេដែក ទឹក កែវ ជីឡាវ ក្រដាសតម្រង ចង្កឹះកែវ ឬឈើ<br>-គ្រូណែនាំសិស្សឱ្យគិតពីប្លង់ពិសោធន៍ និងបង្ហាញគំនិតរបស់គេតាមក្រុម។<br><br>-គ្រូណែនាំបន្ថែម និងប្រាប់ពីបម្រុង | **សម្មតិកម្ម :**<br>-ប្រើវិធីឆក់<br>-ប្រើវិធីចម្រោះ រំហួត<br><br>-សកម្មភាពពិសោធន៍ | -សិស្សគិតពិភាក្សាជាក្រុម ឬជាដៃគូដើម្បីគិតពីប្លង់ពិសោធ<br>+ ប្រើវិធីឆក់យក**ម៉ៅ្យដែក**ឱ្យអស់ដោយប្រើមេដែក<br>+ ចាក់ល្បាយសល់ក្នុងកែវលាយទឹកកូរឱ្យរលាយអំបិលអស់ទុកឱ្យរងទើបច្រោះយក**ខ្សាច់**ចេញ<br>+ យកសូលុយស្យុងថ្លាបានទៅរំហួតដើម្បីបាន**អំបិល** ។<br>-សិស្សសង្កេត និងស្ដាប់ |

| | | |
|---|---|---|
| ប្រយ័ត្ន<br><br><br><br><br>-គ្រូឱ្យសិស្សធ្វើពិសោធន៍តាមក្រុម និងកត់ត្រាការសង្កេត។<br><br><br><br><br><br><br><br><br><br>-គ្រូឱ្យសិស្សឡើងបង្ហាញចម្លើយ ដែលបានពិសោធតាមសំណួរខាងក្រោម៖<br>-តើប្អូនធ្វើដូចម្ដេចដើម្បីយកកម្ទេចដែកចេញពីល្បាយដំបូង?<br>-តើប្អូនធ្វើដូចម្ដេចដើម្បីយកខ្សាច់ចេញពីល្បាយសល់នៅដំណាក់កាលទី២?<br><br><br><br><br>-តើលទ្ធផលដែលបាននៅដំណាក់កាលទី២ជាអ្វីខ្លះ? | <br>(សៀវភៅយោង៖ ស.ស.ទំព័រទី129)<br>-លទ្ធផល និងពិភាក្សា (៥នាទី)<br>+បានកម្ទេចដែកដោយប្រើដែកឆក់<br>+ពេលចាក់ទឹកចូលទទួលបាន អង្គធាតុរាវដែលផ្ទុកភាគល្អិតរឹង (កករវិលវល់)<br>+ខ្សាច់នៅលើតម្រងក្រដាសច្រោះ (កាកសំណល់)<br>+អំបិលជាអង្គធាតុរាវថ្លា(ផលចម្រោះ)<br>+យកសូលុយស្យុងថ្លានេះទៅដាក់នឹងស្លាបព្រាបាយបន្តិច រួចដាក់វាលើអណ្ដាតភ្លើងចង្កៀងអាល់កុលរហូតទទួលបានអង្គធាតុរឹងពណ៌ស(**អំបិល**) | <br><br><br><br><br>-សិស្សទទួលសម្ភារៈ និងអនុវត្តពិសោធន៍តាមក្រុម<br><br><br><br><br><br><br><br><br><br>-តំណាងក្រុមម្នាក់ៗឡើងបំពេញ និងឆ្លើយ ៖<br><br>-ដើម្បីបានកម្ទេចដែកសុទ្ធចេញពីល្បាយ ខ្ញុំយកមេដែកដាក់គូរលើល្បាយស្ងួត ។<br>-ដើម្បីយកខ្សាច់ចេញពីល្បាយសល់ខាងលើខ្ញុំត្រូវ :<br>+ ចាក់ទឹកចូលកូរឱ្យសព្វ<br>+ ប្រើជីឡាវ និងក្រដាសតម្រងដោយច្រោះ យើងទទួលបានខ្សាច់នៅលើក្រដាសតម្រង<br>+ ឯសូលុយស្យុងថ្លាគឺជាទឹកអំបិល<br>-លទ្ធផលដែលបាននៅដំណាក់កាលទី២ ហៅថា៖<br>+ កករវិលវល់(សុលុយស្យុងអំបិល) |

| | | |
|---|---|---|
| -ដើម្បីបានអំបិលរឹងតើប្អូនធ្វើដូចម្តេច?<br>-គ្រូបូកសរុបធ្វើសន្និដ្ឋានជារួម និងឱ្យសិស្សកត់ត្រាខ្លឹមសារសម្រេច ។ | **-សន្និដ្ឋានពិសោធន៍ :** ប្រើមេដែកទាញយកម៉េ្យដែកជាមុន បន្ទាប់ចាក់ទឹកចូលដើម្បីរំលាយអំបិល រួចច្រោះដើម្បីយកដីខ្សាច់ចេញ ចុងក្រោយយកសូលុយស្យុងដែលច្រោះបានទៅរំហួត គេបាន**អំបិលក្រាម** ។ | + កាកសំណល់(ខ្សាច់)<br>+ ផលចម្រោះ(ទឹកអំបិល)<br>-ដើម្បីបានអំបិលយើងធ្វើរំហួតទឹកអំបិល<br><br>-សិស្សកត់ត្រាទុក |
| -តើថ្ងៃនេះយើងបានរៀនវិធីញែកល្បាយអ្វីខ្លះ?<br>-គ្រូបង្ហាញ ដីខ្សាច់ និងរូបគំនូរតុក្កតាគំនិតទី៧៣ "ទឹកស្អាត" មើល រួចបំផុសសំណួរឱ្យសិស្សគិតពិភាក្សា និងឆ្លើយ ។<br><br>-ចម្រោះជាអ្វី ?<br><br>-រំហួតជាអ្វី? | ជំហានទី៤ (១០នាទី)<br>**ពង្រឹងចំណេះដឹង**<br><br>សៀវភៅយោង៖ VVOB ផ្នែកទី២ រូបគំនូរតុក្កតាគំនិតទី៧៣<br>"ទឹកស្អាត" (ធំខាងក្រោម) | -យើងបានរៀនវិធីឆក់ដោយមេដែក វិធីច្រោះ និងវិធីរំហួត<br>-សិស្សសង្កេត គិត និងពន្យល់តាមការយល់ឃើញរបស់ពួកគេ ។<br><br>-ចម្រោះជាការញែកល្បាយអង្គធាតុរឹងពីអង្គធាតុរាវដោយឆ្លងកាត់ជីឡាវមានតម្រងក្រដាស ។<br>-រំហួតគឺជាញែកយកអង្គធាតុរលាយរឹងចេញពីសូលុយស្យុងល្បាយ។ |
| -សរសេរសំណួរលើក្តារខៀន | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ** | -កត់ត្រាចូលសៀវភៅរួចយកទៅធ្វើនៅផ្ទះ ។ |

| | | |
|---|---|---|
| -ដូចម្តេចដែលហៅថាការញែកល្បាយ?<br><br>-ចូរប្អូនៗត្រឡប់ទៅផ្ទះវិញខិតខំស្រាវជ្រាវបន្ថែមដើម្បីរកវិធីញែកល្បាយណាដែលទាក់ទងទៅនឹងជិវភាពប្រចាំថ្ងៃ។ | | -ការញែកល្បាយជាការញែកសារធាតុទាំងឡាយដែលនៅលាយឡំគ្នាឱ្យបិតនៅដាច់ពីគ្នា ។<br>-សិស្សស្តាប់ដោយយកចិត្តទុកដាក់ ។ |

សៀវភៅណែនាំគ្រូរបស់ VVOB ផ្នែកទី២ រូបគំនូរតុក្កតាគំនិតទី៧៣ "ទឹកស្អាត"



# **ផែនការបង្រៀន** (C921)

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី២ ៖ កាបូន អុកស៊ីសែន និងអ៊ីដ្រូសែន
- រយៈពេល ៖ ០៥ ម៉ោងសិក្សា

## I- វត្ថុបំណង ៖

បន្ទាប់ពីសិក្សាមេរៀនចប់សិស្សនឹងអាច ៖

- ពណ៌នាពីលក្ខណៈរូប និងលក្ខណៈគីមីរបស់កាបូន
- ឱ្យឈ្មោះសណ្ឋានវិសមរូបរបស់កាបូន(ក្រាភីត និង ពេជ្រ)
- ពណ៌នាពីប្រតិកម្មទង្វើកំបោររស់ពីថ្មកំបោរ
- អនុវត្តបម្រើបម្រាស់ និងកំបោរងាប់ក្នុងជីវភាព

## II-ផែនការបង្រៀន ៖

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល 5 ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន**

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. កាបូនក្នុងធម្មជាតិ<br>2. លក្ខណៈរូប | 114-115 |
| 1 | 3. លក្ខណៈគីមី | 115-116 |
| 1 | 4. អុកស៊ីតរបស់កាបូន | 116-117 |
| 1 | 5. កាបូណាត<br>6. កាល់ស្យូមកាបូណាត | 117-118 |
| 1 | 7.ទង្វើកំបោររស់និងកំបោរងាប់<br>សង្ខេបមេរៀន<br>សំណួរ | 118-119 |

សៀវភៅយោង ៖ ស.ស. / STEPSAM3:

## III.ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីសិស្ស ៖

- ពណ៌នាពីលក្ខណៈរូប និងលក្ខណៈគីមីរបស់កាបូន
- ឱ្យឈ្មោះសណ្ឋានវិសមរូបរបស់កាបូន (ក្រាភីត និង ពេជ្រ)

- ពណ៌នាពីប្រតិកម្មទង្វើកំបោររស់ពីថ្មកំបោរ
- អនុវត្តបម្រើបម្រាស់ និងកំបោរងាប់ក្នុងជីវភាព

## IV.ខ្លឹមសារពិបាក ៖

- ក្នុងមេរៀននេះ គ្រប់ពិសោធន៍ទាំងអស់មិនស្រួលអនុវត្តទេគ្រូត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំមុនបង្រៀន និងបើសិនជាមានគ្រូដែលមានបទពិសោធន៍ច្រើន ឬប្រធានក្រុមបច្ចេកទេសអាចរកជំនួយបាន ។

## V. ពិសោធន៍ និងសម្មភាពបន្ថែម ៖

សៀវភៅយោង៖ ស.ស. និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3 "កាបូនអំពើជាមួយអុកស៊ីសែន" ($C+O_2$ -> $CO_2$)

| សម្ភារៈ ៖ ពិសេស | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| អគ្គិសនីវិភាគ<br>ទឹក NaOH (3%)<br>ដែកគោល (២)<br>ថ្មពិល៩វ៉ុល<br>ខ្សែអគ្គិសនី បំពង់សាក<br>ឆេះកាបូន ធ្យូង<br>ស្លាបព្រាវែង | ៣០-៦០នាទី | ២០-៤០នាទី<br>(៤០នាទីបើគ្រូបង្ហាញឱ្យសិស្សមើលអគ្គិសនីវិភាគ) | ខ្ពស់ | គ្រូបង្ហាញ |

ពិសោធន៍នេះត្រូវការសម្ភារៈច្រើន និងពេលវេលាយូរ។ ដូចនេះ គ្រូអាចបង្ហាញរូបភាពនៅខាងស្តាំដែលមានកាបូនឆេះក្នុងអុកស៊ីសែនសុទ្ធ និងបន្ទាប់មកសិស្សអាចប្រៀបធៀបរូបភាព និងអ្វីដែលគេដឹងអំពីកាបូនដូចជាធ្យូងឆេះក្នុងខ្យល់។



សៀវភៅយោង៖ ស.ស. និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនរបស់ STEPSAM3 "អំពើលើអុកស៊ីតលោហៈ" (ឧទាហរណ៍ CuO)

| សម្ភារៈ ៖ ពិសេស | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| គ្រឿងកម្តៅអុកស៊ីតII ទង់ដែង(CuO) បំពង់សាក និងឆ្នុក កែវ បំពង់ ទឹកកំបោរថ្លា | ២០-៤០នាទី | ១៥-៣០នាទី (៤០នាទីបើគ្រូបង្ហាញឱ្យសិស្សមើលអគ្គិសនីវិភាគ) | ខ្ពស់ | គ្រូបង្ហាញ |

សៀវភៅយោង៖ ស.ស. និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3 "តេស្តឧស្ម័ន $CO_2$ "

| សម្ភារៈ ៖ ពិសេស | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| ទឹកកំបោរថ្លា HCl អាស៊ីតក្លរីឌ្រិច $CaCO_3$ កាល់ស្យូមកាបូណាត បំពង់សាក ឆ្នុក និង បំពង់កែវ | ១០-១៥នាទី គ្រូត្រូវធ្វើទឹកកំបោរថ្លាចាំបាច់មួយថ្ងៃមុននឹងបង្រៀន | ១០-១៥នាទី | មធ្យម | គ្រូបង្ហាញ |

**សម្គាល់៖** សៀវភៅណែនាំគ្រូរបស់ VSO ណែនាំអំពីរបៀបផលិតទឹកកំបោរ៖ គីមីវិទ្យាថ្នាក់ទី៧ ជំពូកទី៣ មេរៀនទី១ នៅសៀវភៅ VSO ទំព័រទី៦៧

សៀវភៅយោង៖ សៀវភៅណែនាំគ្រូរបស់ VSO "តើធ្វើដូចម្តេចដើម្បីតេស្តរកកាបូននៅក្នុងសារធាតុមួយ?"

| សម្ភារៈ ៖ ធម្មតា / ពិសេស | ពេលវេលារៀបចំ | ពេលវេលាអនុវត្ត | កម្រិតនៃការលំបាក | គ្រូបង្ហាញ ឬ សិស្សចូលរួម |
|---|---|---|---|---|
| គ្រឿងកម្តៅ ស្លាបព្រា ដង្កៀប អាស៊ីត (HCl) (ឧ.ទឹកលាងបង្គន់ ឬ ទឹកខ្មេះ) គ្រប់អង្គរមួយចំនួន កញ្ចក់ កៅស៊ូ ដីខ្សាច់ ប្លាស្ទិក ក្រណាត់ ខ្យង (ពងមាន់) ស្លឹកអាលុយមីញ៉ូម | ១០នាទីឡើងទៅ | ៣០-៤០ នាទី | មធ្យម / ពិបាក | គ្រូបង្ហាញ (សិស្សអាចចូលរួមសកម្មភាពមួយចំនួនបាន) |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមានមធ្យោបាយអនុវត្តបាននោះនឹងទទួលបានលទ្ធផលសិក្សាល្អ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី២ ៖ កាបូន អុកស៊ីសែន អ៊ីដ្រូសែន
- មេរៀនទី១ ៖ កាបូន
- ម៉ោងទី ៖ ១
- ប្រធានបទ ៖ **កាបូនក្នុងធម្មជាតិ និងលក្ខណៈរូបកាបូន**
- រយៈពេល : ០១ម៉ោងសិក្សា (៥០នាទី)

**I. វត្ថុបំណង ៖**

- ចំណេះដឹង : ពណ៌នាពីកាបូនក្នុងធម្មជាតិ និងលក្ខណៈរូបរបស់កាបូនតាមរយៈពិសោធន៍ និងសំណួររបស់គ្រូដោយផ្អែកតាមសៀវភៅសិក្សាគោលបានត្រឹមត្រូវ
- បំណិន : ញែកសម្គាល់ពីលក្ខណៈខុសគ្នានៃទម្រង់របស់កាបូនជាពេជ្រ និងក្រាភីត តាមរយៈការសង្កេតពិសោធន៍ និងគំរូអាតូមកាបូនបានត្រឹមត្រូវ
- ឥរិយាបថ : ឱ្យសិស្សចូលចិត្តលើការសង្កេតស្រាវជ្រាវពីកាបូនដែលមានប្រើ ក្នុងជីវភាពប្រចាំថ្ងៃ និងក្នុងធម្មជាតិ ។

**II. សម្ភារៈបង្រៀន និងរៀន ៖**

**- សៀវភៅយោង :**

+ សៀវភៅសិក្សាគោលថ្នាក់ទី៩ ទំព័រទី 114 ដល់ទំព័រទី 145

+ សៀវភៅសិក្សាគោលថ្នាក់ទី៧ រូបវិទ្យា ជំពូគទី៣ មេរៀនទី២ "ចរន្តអគ្គិសនី")

+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3 ទំព័រទី55 ដល់ទំព័រទី66 ។

**- សម្ភារៈពិសោធន៍ :**

+ គំរូអាតូមកាបូន : ប្រេងកាត(ប្រេងឆា) កំណាត់សំពត់ ដែកកេះ អង្គរ ធ្យូង ថ្មពិល បណ្តូលថ្មពិល អំពូល និងខ្សែចម្លង (បើគ្មានខ្លះ អាចអនុវត្តតាមសម្ភារៈដែលមានបាន)

+ តារាងសម្រាប់បំពេញចម្លើយលក្ខណៈខុសគ្នារវាងពេជ្រ និងក្រាភីត ។

*** កំណត់សម្គាល់ :**

+ បើគ្មានគំរូអាតូមកាបូន គ្រូអាចឱ្យសិស្សរកឈើចាក់ធ្មេញ ផ្លែក្រខុប ឬអ្វីដែលអាចជំនួសបាន

+ គ្រូត្រូវត្រៀមធ្វើតារាងសម្រាប់បំពេញចម្លើយលក្ខណៈខុសគ្នារវាងពេជ្រ និងក្រាភីត ដោយប្រើក្រដាសកាតុង ស្រោមប្លាស្ទិចថ្លាបានជាការល្អព្រោះអាចប្រើម្តងហើយម្តងទៀតបាន

+ វិធីបង្រៀន និងរៀនតាមបែបរិះរក (IBL)។

### III. សកម្មភាពបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្តាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្រប សម្រួល ឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -បំផុសសំណួរដូចជា ៖<br>១.តើធាតុគីមីនៅក្រុម/ជួរឈរទី1 (លោហ:អាល់កាឡាំង) មានធាតុអ្វីខ្លះ?<br><br>២.តើធាតុគីមីនៅក្រុម/ជួរឈរទី17 ជាលោហ: ឬអលោហ:? ចូរប្រាប់ឈ្មោះធាតុគីមីរបស់វាឱ្យបានពីរ។<br>៣.តើកាបូនជាធាតុគីមីស្ថិតនៅក្នុងក្រុមខួបណាមួយនៃតារាងខួបគីមី?<br>-សួរសំណួរភ្ជាប់មេរៀន៖<br>១.តើប្អូនស្គាល់កាបូនដែរឬទេ?<br>២.កាបូនមាននៅកន្លែងណាខ្លះ? | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br>- ធាតុគីមីក្រុម1លោហ:អាល់កាឡាំង<br><br>- ធាតុគីមីក្រុម17 និងលក្ខណ:វា | -គិត ហើយឆ្លើយលើក្តារឆ្នួន<br>១.ធាតុគីមីស្ថិតនៅក្នុងក្រុម1(លោហ: អាល់ កាឡាំងមានធាតុ: លីចូម (Li) សូដ្យូម (Na) ប៉ូតាស្យូម (K) រុយប៊ីដ្យូម (Rb) សេស្យូម (Cs) និងប្រង់ស្យូម (Fr)។<br>២.ធាតុគីមីនៅក្រុម/ជួរឈរទី17ជាអលោហ: ដែលសកម្មខ្លាំង ភ្លុយអរ (F) ក្លរ (Cl)។<br>៣.ក្រុមទី14ខួបទី2 ឬក្រុមIVAខួបទី2<br><br>-គិតគិត រួចឆ្លើយ<br>១.ស្គាល់/មិនស្គាល់<br>២.កាបូនមាននៅក្នុងធ្យូង បណ្តូលខ្មៅដៃ បណ្តូលថ្មពិល... |
| -ទុកពេលឱ្យសិស្សគិត និងឆ្លើយសាកល្បងជាបុគ្គលនូវលក្ខណ:រូបរបស់កាបូន។<br>-ថ្ងៃនេះយើងនឹងពិនិត្យលើលក្ខណ:រូបបីរបស់កាបូនគឺពណ៌ ទម្រង់អាតូម និងលក្ខណ:ចម្លងអគ្គិសនី។ | ជំហានទី៣ (៣០នាទី)<br>**មេរៀនថ្មី**<br>**កាបូនក្នុងធម្មជាតិ និង**<br>**លក្ខណ:រូបកាបូន** | -ចម្លើយសិស្សអាច៖ កាបូនមានលក្ខណ:រូបដូចជា ពណ៌ខ្មៅ ជាអង្គធាតុរឹង ស្រួយ ចម្លងចរន្តអគ្គិសនី ចម្លងកម្តៅ ។ល។ |
| **សំណួរគន្លឹះ ៖ តើកាបូនមានលក្ខណ:រូបដូចម្តេចខ្លះ?** | | |

| | | |
|---|---|---|
| <u>សកម្មភាពទី១</u> (១០នាទី)<br>**ការសង្កេតពណ៌ និងវត្ថុមានកាបូនក្នុងសារធាតុផ្សេងៗ** | | <u>សកម្មភាពទី១</u><br>(សិស្សចូលរួមតាមការណែនាំពីគ្រូ... ឧទាហរណ៍ ជួយប្រើប្រាស់សម្ភារៈ... ។ល។) |
| -តើកាបូនមានពណ៌អ្វី? មាននៅកន្លែងណាខ្លះ?<br>-គ្រូឱ្យសិស្សសង្កេត និងកត់ត្រា លទ្ធផលចំហេះក្រដាស ប្រេងកាត (ប្រេងឆា) អង្ករ និងកំណាត់សំពត់។<br>-បំផុសសំណួរ :<br>១.តើផលិតផលដែលបានពីចំហេះសារធាតុខាងលើជាអ្វីខ្លះ? | -សង្កេត ចំហេះរបស់ក្រដាស ប្រេងកាត (ប្រេងឆា) អង្ករ និង កំណាត់សំពត់។<br>-សំណួរបំផុសលទ្ធផលចំហេះសារធាតុនីមួយៗ :<br>**ក្រដាស** មានផ្សែងគ្មានពណ៌ ($CO_2$) ផ្សែងខ្មៅ(C) និងផេះ<br>**ប្រេងកាត** ផ្សែងគ្មានពណ៌ ផ្សែងខ្មៅ<br>**អង្ករ** ផ្សែង និងធ្យូង<br>**កំណាត់សំពត់** ផ្សែង និងផេះ។ | -កាបូនមានពណ៌ខ្មៅ ហើយមាននៅក្នុងធ្យូងបណ្ដូលខ្មៅដៃ...។<br>-សិស្សសង្កេតតាមដាននូវរាល់ចំហេះសារធាតុនីមួយៗ និងកត់ត្រាលទ្ធផល។<br>-ពិភាក្សាគ្នាជាដៃគូរ រួចឆ្លើយ<br>១.ម្រែងភ្លើង ផេះ និងឧស្មន័កាបូនឌីអុកស៊ីត($CO_2$) ជាឧស្ម័នគ្មានពណ៌។ |
| ២.តើផលចំហេះមួយណាដែលបញ្ជាក់ថាសារធាតុទាំងនោះមានផ្ទុកកាបូន? | -ផ្សែងពណ៌ខ្មៅ និងផេះពណ៌ខ្មៅបញ្ជាក់ពីវត្ថុមានកាបូន។ | ២.ផ្សែងពណ៌ខ្មៅ និងផេះពណ៌ខ្មៅបញ្ជាក់ពីវត្ថុមានកាបូន។ |
| ៣.ប្រាប់សិស្សពីផ្សែងខ្មៅគឺជាផង់កាបូន ជាអង្គធាតុរឹងមិនមែនជាឧស្ម័ន។ | -ផ្សែងខ្មៅជាផង់កាបូន។ | ៣.ស្ដាប់ និងកត់ត្រា |
| ៤.តើប្អូនគិតថាកាបូនមានសារធាតុអ្វីខ្លះក្នុងធម្មជាតិ? | | ៤.សន្និដ្ឋាន : មានក្នុងអាហារ រុក្ខជាតិ សត្វ ប្រេងឥន្ធនៈ សសៃរ កំណាត់សំពត់ (សំលៀកបំពាក់)។ |
| <u>សកម្មភាពទី២</u> (៥នាទី)<br>**សង្កេតគំរូអាតូមកាបូន** | | <u>សកម្មភាពទី២</u> |
| -ដំឡើងគំរូអាតូមកាបូនជា២ទម្រង់ក្រាភីត និងពេជ្រ ឱ្យសិស្សសង្កេតរូបភាព | -សង្កេតពីអាតូមកាបូនទម្រង់ជាក្រាភីត និងពេជ្រ | -សង្កេតរួមគ្នាបន្ទាប់គិតពិភាក្សាជាដៃគូហើយឆ្លើយសំណួរ |
| -បំផុសសំណួរ :<br>តើការតម្រៀបអាតូមកាបូនក្នុង | -ការតម្រៀបអាតូមកាបូនជា | -កាបូនក្រាភីតជាស្រទាប់កាបូន៦ |

<table>
<tr>
<td>ទម្រង់ក្រាភីតដូចម្តេច?<br><br>(សំណួរបន្ថែមពី STEPSAM3 ៖ តើមានគំរូអាតូមកាបូនមួយទៀតដែរឬទេ?)<br><br><u>សកម្មភាពទី៣ (១៥នាទី)</u><br>លក្ខណៈចម្លងចរន្តអគ្គិសនី<br>-យកឧបករណ៍សម្រាប់ធ្វើតេ្តសលទ្ធភាពចម្លងចរន្តអគ្គិសនី និងសារធាតុមួយចំនួនដូចជា ធ្យូង បណ្តូរខ្មៅដៃ ចែកឱ្យសិស្សតាមតុ ឬក្រុម (តាមលទ្ធភាពជាក់ស្តែង)។<br>-បំផុសសំណួរ ៖<br>តើធ្យូង ឬបណ្តូរខ្មៅដៃមានភាពចម្លងចរន្តអគ្គិសនីដែរឬទេ?<br>-ពន្យល់ពីលក្ខណៈរបស់កាបូនមានទម្រង់ជាពេជ្រ។</td>
<td>ក្រាភីត ស្រទាប់ឆកោណ (កាបូន ៦ជ្រុង)<br>ពេជ្រ ជាបណ្តាញចតុមុខ (កាបូន៤ជ្រុង)<br>កាបូនបំពង់ណាណូ (Nano tube) រឹងមាំ និងស្រាល<br><br>-ឱ្យសិស្សធ្វើតេស្តភាពចម្លងចរន្តអគ្គិសនីរបស់កាបូនជាក្រាភីត<br>*អំពូលភ្លឺនាំឱ្យធ្យូង ឬក្រាភីតចម្លងចរន្តអគ្គិសនី។<br>(សៀវភៅយោង៖ ស.ស.វិទ្យាសាស្ត្រ ថ្នាក់ទី៧ រូបវិទ្យា ជំពូកទី៣ មេរៀនទី២ "ចរន្តអគ្គិសនី")<br><br>-ពេជ្រគ្មានពណ៌ របឹង(ភាពរឹង) និងមិនចម្លងចរន្តអគ្គិសនី</td>
<td>ជ្រុង<br>-កាបូនពេជ្រមានបណ្តាញកាបូនរាងចតុមុខ ឬកាបូនមុខបួន<br>(មានកាបូនបំពង់ណាណូ (Nano tube) និងទម្រងផ្សេងៗដែលប្រើប្រាស់ក្នុងឡាន ឬក្នុងកីឡា ពិព្រោះវារឹងមាំ និងស្រាល)<br><u>សកម្មភាពទី៣</u><br><br>-ទទួលសម្ភារៈ និងអនុវត្តតាមតុ ឬក្រុមតាមការចាត់ចែងរបស់គ្រូ។<br><br>-គិតរួចឆ្លើយ<br>ធ្យូង និងបណ្តូរខ្មៅដៃ ធ្វើឱ្យអំពូលភ្លើងភ្លឺ ដូច្នេះវាចម្លងចរន្តអគ្គិសនី។<br>-ស្តាប់ និងកត់ត្រា</td>
</tr>
<tr>
<td>-ឱ្យសិស្សធ្វើការសន្និដ្ឋានសរុបលើលក្ខណៈខុសគ្នារវាងកាបូនទម្រង់ជាពេជ្រ និងក្រាភីតដោយបំពេញក្នុងតារាង។</td>
<td>ជំហានទី៤ (១០នាទី)<br>ពង្រឹងចំណេះដឹង<br>-ពណ៌ របឹង ការចម្លងចរន្ត អគ្គិសនី និងការតម្រៀបអាតូម
<table>
<tr><td></td><td>ពេជ្រ</td><td>ក្រាភីត</td></tr>
<tr><td>ពណ៌</td><td></td><td></td></tr>
<tr><td>របឹង</td><td></td><td></td></tr>
<tr><td>ចម្លងចរន្ត</td><td></td><td></td></tr>
<tr><td>ការតម្រៀបអាតូម</td><td></td><td></td></tr>
</table>
សៀវភៅយោង៖ STEPSAM3</td>
<td>-តំណាងសិស្សដែលគ្រូចាប់ឆ្នោតឡើងបំពេញតារាង
<table>
<tr><td></td><td>ពេជ្រ</td><td>ក្រាភីត</td></tr>
<tr><td>ពណ៌</td><td>គ្មានពណ៌</td><td>ប្រផេះក្រមៅ</td></tr>
<tr><td>របឹង</td><td>រឹង</td><td>ផុយ</td></tr>
<tr><td>ចម្លងចរន្ត</td><td>មិនចម្លង</td><td>ចម្លងបានល្អ</td></tr>
<tr><td>ការតម្រៀបអាតូម</td><td>កាបូនចតុមុខ</td><td>ស្រទាប់ឆកោណ</td></tr>
</table></td>
</tr>
</table>

| | | |
|---|---|---|
| | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ** | |
| -សរសេរសំណួរឱ្យសិស្សធ្វើកិច្ចការផ្ទះ។<br>១.តើកាបូនត្រូវបានគេប្រើសម្រាប់ធ្វើអ្វីខ្លះក្នុងជីវភាពប្រចាំថ្ងៃ? | <br><br>-បម្រើបម្រាស់កាបូន | -កត់ត្រាដោយយកចិត្តទុកដាក់<br>១.កាបូនត្រូវបានគេប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃដូចជា៖<br>+អេឡិចត្រូតក្នុងជើងអគ្គិសនីវិភាគ បណ្តូលខ្មៅដៃ<br>+គ្រឿងអលង្ការ(ពេជ្រ)<br>+ប្រដាប់កាត់កញ្ចក់(ពេជ្រ)<br>+ឡាន និងកង់កីឡា (បំពង់ណាណូ (Nano tube)) |
| ២.ហេតុអ្វីបានជាគេប្រើកាបូនទម្រង់ក្រាភីតជាបណ្តូរខ្មៅដៃ? | -តួនាទីកាបូន | ២.បានជាគេប្រើកាបូនទម្រង់ក្រាភីតជាបណ្តូលខ្មៅដៃព្រោះវាផុយ និងបង្កើតជាស្នាមគំនូសនៅលើក្រដាសបាននៅពេលយើងសរសេរ។ |

## **ផែនការបង្រៀន** ( C932 )

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី៣ ៖ អុកស៊ីត អាស៊ីត បាស និងអំបិល
- រយៈពេល ៖ ០៤ ម៉ោងសិក្សា

### I- វត្ថុបំណង ៖

បន្ទាប់ពីសិក្សាមេរៀនចប់សិស្សនឹងអាច ៖

- ពណ៌នានិយមន័យអាស៊ីត
- ពណ៌នាលក្ខណៈរបស់អាស៊ីត(ប្រតិកម្មជាមួយបាស លោហៈ)
- ពណ៌នាអាស៊ីតសំខាន់មួយចំនួននិងបម្រើបប្រាស់

### II-ផែនកាបង្រៀន ៖

មេរៀននេះត្រូវបានបែងចែកសម្រាប់បង្រៀន និងរៀនរយៈពេល ៩ ម៉ោង ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបំណែងចែកម៉ោងបង្រៀន**

| ម៉ោងសិក្សា | ចំណងជើងរងមេរៀន | ទំព័រក្នុងសៀវភៅសិស្ស |
|---|---|---|
| 1 | 1. និយមន័យ<br>2. លក្ខណៈរបស់អាស៊ីត | 138 - 139 |
| 1 | 3. លក្ខណៈគីមីរបស់អាស៊ីត<br>3.1 អំពើជាមួយលោហៈ<br>3.2 អំពើជាមួយកាបូណាត<br>3.3 អំពើជាមួយអុកស៊ីតលោហៈ និងអ៊ីដ្រុកស៊ីត<br>3.4 អត្តសញ្ញាណអាស៊ីត | 139 - 140 |
| 1 | 4.អាស៊ីតសំខាន់ៗ និងបម្រើបម្រាស់<br>4.1 អាស៊ីតក្លរីឌ្រិច<br>4.2 អាស៊ីតស៊ុលផួរិច<br>5. បម្រើបម្រាស់អាស៊ីត | 140 - 142 |
| 1 | សង្ខបមេរៀន<br>សំណួរ និងលំហាត់ | 143 |

សៀវភៅយោង ៖ ស.ស. / STEPSAM3:

### III.ចំណុចនៃការបង្រៀន ៖

ការបង្រៀនមេរៀននេះគឺដើម្បីសិស្ស ៖

- ពណ៌នានិយមន័យអាស៊ីត និងលក្ខណៈរូបអាស៊ីត
- ពណ៌នាលក្ខណៈគីមីរបស់អាស៊ីត(ប្រតិកម្មជាមួយបាស លោហៈ)
- ពណ៌នាអាស៊ីតសំខាន់មួយចំនួននិងបម្រើប្រាស់

**IV.ខ្លឹមសារពិបាក ៖**

**សិស្សអាចជួបការលំបាកលើបញ្ញាតិខាងក្រោម៖**

- រូបមន្តគីមីអាស៊ីតសរីរាង្គ មួយដូចជា អាស៊ីតអាសេទិច អាស៊ីតតាកទ្រិច អាស៊ីតទ្រិច ....
- ការសរសេរសមីការតាងប្រតិកម្ម អាស៊ីត និងបាស អាស៊ីតជាមួយលោហៈចំនួន
- ការធ្វើពិសោធន៍ ប្រតិកម្ម អាស៊ីត ជាមួយបាស អាស៊ីតជាមួយលោហៈចំនួន

  ដូចនេះ គ្រូត្រូវមានបម្រុងប្រយ័ត្ននៅក្នុងមេរៀននេះព្រោះគ្រប់ពិសោធន៍ទាំងអស់មិនស្រួលអនុវត្តទេ គ្រូត្រូវយកចិត្តទុកដាក់ត្រៀមរៀបចំ មុនបង្រៀន និងបើសិនជាមានគ្រូដែលមានបទពិសោធន៍ច្រើន ឬប្រធានក្រុមបច្ចេកទេសជួយជាការល្អ។

**V. ពិសោធន៍ និងសម្មភាពបន្ថែម ៖**

គ្រូអាចជ្រើសរើសសកម្មភាព/ពិសោធន៍តែមួយដើម្បីអនុវត្តក្នុងមេរៀននេះដោយផ្អែកតាមសៀវភៅយោងមួយចំនួនដូចជា ៖

១. សៀវភៅយោង៖ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3 ទំព័រទី89-111
សៀវភៅណែនាំគ្រូរបស់ VVOB ទំព័រទី34-52
សៀវភៅណែនាំគ្រូរបស់ VSOទំព័រទី295-296

**ស្តីពី អត្តសញ្ញាណកម្មអាស៊ីត បាស ដោយក្រដាស pH និង ទឹកផ្កាក្រហម**

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលារៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| កែវប៊ែស៊ែ សំបកដបទឹកសុទ្ធថ្លា បំពង់សាក ជើងទម្រ ពីប៉ែតក្រដាស ទឹកផ្ការំយោល ទឹកក្រូចឆ្មារ ទឹកខ្មេះ ផ្លែប៉ោម ទំពាំងបាយជូ ទឹកទៀបបារាំង ទឹកលាងបង្កន់ កូកាកូឡា ទឹកភ្លៀង ទឹកសូដា ស៊ូត ម្សៅមេនំ ($NaHCO_3$) | មួយថ្ងៃ ទៅពីរថ្ងៃ | ១៥នាទី | មធ្យម<br>គ្រូអាចធ្វើបាន | គ្រូ និងសិស្ស |

ចំណាំ ៖ ពិសោធន៍នេះត្រូវការសម្ភារៈច្រើន និងពេលវេលាយូរ ។ ដូចនេះ គ្រូត្រូវរៀបចំមុនពីរថ្ងៃយ៉ាងតិច និងមានបម្រុងប្រយ័ត្នខ្ពស់ ។

២. សៀវភៅយោង៖ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3:

**ស្តីពី លក្ខណៈគីមីអាស៊ីត**

- ប្រតិកម្មអាស៊ីត ជាមួយ បាស NaOH
- ប្រតិកម្មអាស៊ីតជាមួយ អំបិល $CaCO_3$
- ប្រតិកម្មអាស៊ីត ជាមួយលោហៈ Al Zn Fe Cu

| **សម្ភារៈ ៖ ធម្មតា** | **ពេលវេលា រៀបចំ** | **ពេលវេលាអនុវត្ត** | **កម្រិតនៃការលំបាក** | **គ្រូបង្ហាញ ឬ សិស្សចូលរួម** |
|---|---|---|---|---|
| $CaCO_3$ ថ្មកំបោរ សំបកលៀស<br>CaO កំបោររស់<br>NaOH មេសាប៊ូ<br>$Ca(OH)_2$ ទឹកកំបោរថ្លា<br>HCl ទឹកសាប៊ូលាងបង្គន់<br>$H_2SO_4$ អាស៊ីតអាគុយ<br>Al (សំបកកំប៉ុងទឹកក្រូច)<br>Fe (ដែកគោលឬលោហៈស្រោមពីក្រៅថ្មពិល)<br>Zn (លោហៈខាងក្នុងថ្មពិល)<br>Cu (បណ្តូរខ្សែភ្លើង)<br>កែវប៊េស៊ែ សំបកដបទឹកសុទ្ធថ្លា<br>បំពង់សាក ជើងទម្រ ពីប៉ែត | មួយថ្ងៃ | ២០នាទី ទៅ ៣០ នាទី | មធ្យម | គ្រូ និងសិស្ស |

សកម្មភាពខាងលើត្រូវប្រើប្រាស់សម្ភារៈច្រើន។ គ្រូអាចប្រើប្រាស់មួយចំនួនឬកែសម្រួលតាមជាក់ស្តែង ប៉ុន្តែបើគ្រូមានមធ្យោបាយអាចអនុវត្តបាន នោះនឹងទទួលបានលទ្ធផលសិក្សាល្អប្រសើរ ។

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គីមីវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី៣ ៖ អុកស៊ីត អាស៊ីត បាស និងអំបិល
- មេរៀនទី២ ៖ អាស៊ីត
- ម៉ោងទី ៖ ១
- ប្រធានបទ ៖ **និយមន័យ និងលក្ខណៈរបស់អាស៊ីត**
- រយៈពេល ៖ ០១ម៉ោងសិក្សា (៥០នាទី)

**I. វត្ថុបំណង ៖**

- ចំណេះដឹង ៖ ពណ៌នាពីនិយមន័យ និងលក្ខណៈរូបរបស់អាស៊ីតតាមរយៈការសង្កេតពិសោធន៍ និងសំណួរបំផុសរបស់គ្រូបានត្រឹមត្រូវ
- បំណិន ៖ កំណត់អត្តសញ្ញាណកម្មអាស៊ីតមួយចំនួនក្នុងជីវភាពប្រចាំថ្ងៃតាមរយៈការពិសោធដោយប្រើក្រដាសpH និងទឹកស្ពៃក្តោបពណ៌ស្វាយ ឬទឹកផ្កាក្រហមបានត្រឹមត្រូវ
- ឥរិយាបថ ៖ សិស្សមានបម្រុងប្រយ័ត្នចំពោះអាស៊ីតដែលបង្កគ្រោះថ្នាក់ និងការប្រើប្រាស់អាស៊ីតក្នុងជីវភាពប្រចាំថ្ងៃ ។

**II. សម្ភារបង្រៀន និងរៀន ៖**

**- សៀវភៅយោង ៖**

+ សៀវភៅសិក្សាគោលថ្នាក់ទី៩ ទំព័រទី138 ដល់ទំព័រទី139
+ សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី៩របស់ STEPSAM3 ទំព័រទី101 ដល់ទំព័រទី102
+ សៀវភៅរបស់ VVOB (ពិសោធន៍គីមី) ទំព័រទី44 ដល់ទំព័រទី45
+ សៀវភៅរបស់ VSO ទំព័រទី295 ដល់ទំព័រទី296 ។

**- សម្ភារពិសោធ ៖**

+ ក្រដាសpH អង្គធាតុចង្អុលពណ៌ ទឹកស្ពៃក្តោបពណ៌ស្វាយ (ផ្ការំយោលក្រហម ឬប្រទាលល័ក្ខ ស្វាយ)
+ បំពង់សាក កែវបេស៊ែ ពីប៉ែត
+ ក្រូចឆ្មារ ទឹកខ្មេះ ទឹកលាងបង្គន់ ទឹកសូដា ទឹកទំពាំងបាយជូរ ស្វាយ ប៉េងប៉ោះ ភេសជ្ជៈcoca cola ។

*** កំណត់សម្គាល់ ៖**

+ គ្រូអាចអនុវត្តមេរៀននេះតាមសម្ភារៈដែលអាចរកបាន
+ វិធីបង្រៀន និងរៀនតាមបែបរិះរក (IBL)។

**III. សកម្មភាពបង្រៀន និងរៀន ៖**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
| --- | --- | --- |
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្ដាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២នាទី)<br>**រដ្ឋបាលថ្នាក់** | -ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួល ឡើងរាយការណ៍ពីអវត្តមានសិស្ស។ |
| -បំផុសសំណួរផ្ទាល់មាត់ដូចជា ៖<br>១.ដូចម្ដេចដែលហៅថាអុកស៊ីត?<br>២.បណ្ដារូបមន្ត $Na_2O$ $CO_2$ $CaO$ $SO_2$ $Al_2O_3$ $P_2O_5$ … តើរូបមន្តណាខ្លះជាអុកស៊ីតអាស៊ីត?<br>៣.បើគ្រូយកអុកស៊ីតអាស៊ីតខាងលើទៅដាក់ជាមួយទឹកយើងទទួលបានអ្វី?<br>-ពោលះថ្ងៃនេះយើងនឹងសិក្សាអំពី "អាស៊ីត" | ជំហានទី២ (៥នាទី)<br>**រំឭកមេរៀនចាស់**<br>- និយមន័យអុកស៊ីត<br>-ញែកសម្គាល់ប្រភេទអុកស៊ីតអាស៊ីត<br>- ប្រតិកម្មរវាងអុកស៊ីតអាស៊ីត និងទឹក ($H_2O$) | - ស្ដាប់ និងគិត សរសេរចម្លើយលើក្ដារឆ្នួន ៖<br>១.អុកស៊ីតជាសមាសធាតុដែលផ្សំដោយ ធាតុពីរយ៉ាងដែលមានមួយជាអុកស៊ីសែន។<br>២. $CO_2$ $SO_2$ និង$P_2O_5$ ជាអុកស៊ីតអាស៊ីត<br>៣.ទទួលបាន**អាស៊ីត** ។ |
| | ជំហានទី៣ (៣០នាទី)<br>**មេរៀនថ្មី**<br>**និយមន័យ និងលក្ខណៈរបស់អាស៊ីត** | |
| **សំណួរគន្លឹះ :** ដូចម្ដេចដែលហៅថាអាស៊ីត? តើអាស៊ីតមានលក្ខណៈយ៉ាងដូចម្ដេច? | | |
| -លើកឧទាហរណ៍ ឬយកផ្លែឈើមួយចំនួនដូចជា ផ្លែស្វាយខ្ចី ប៉ម ក្រូច និងផ្លែទំពាំងបាយជូរ ។ | -សង្កេតពីផ្លែឈើដែលមានរសជាតិជូរមួយចំនួន ។ | -សង្កេត គិតរួចហើយសរសេរចម្លើយលើក្ដារឆ្នួន |

| | | |
|---|---|---|
| រួចបំផុសសំណួរ ៖ ១.តើផ្លែឈើទាំងនេះមានរសជាតិដូចម្តេច ? ២.តើសារធាតុដែលមានរសជាតិជូរគេចាត់ទុកជាសារធាតុអ្វី ? | សារធាតុចង្អុលពណ៌ | ១.មានរសជាតិ**ជូរ** ។ ២.សារធាតុដែលមានរសជាតិជូរគេចាត់ទុកជា**អាស៊ីត** ។ |
| -សរសេររូបមន្តអាស៊ីតមួយចំនួនដូចជា HCl $H_2CO_3$ $H_2SO_4$... តើក្នុងរូបមន្តនេះមានធាតុអ្វីជារួមដូចគ្នា ? | -អាស៊ីតមានធាតុអ៊ីដ្រូសែន(H) ក្នុងរូបមន្តវាដូចៗគ្នា ។ | -អំបិល + ទឹក -មានធាតុអ៊ីដ្រូសែន(H) ។ |
| -បើគ្រូមានសូលុយស្យុងពីរ មួយជាអាស៊ីតHCl និងមួយជាស៊ូត រួចចាក់លាយបញ្ចូលគ្នា តើយើងទទួលបានអ្វី? | -បន្តក់សូលុយស្យុង HCl និងNaOH ដាក់កូនស្លាបព្រាបន្តិចតេស្តដោយអណ្តាត ភ្លើងទៀនគេទទួលក្រាមពណ៌ស(ជាអំបិល)។ | -ស្តាប់ និងគិត |
| -ឱ្យសិស្សធ្វើពិសោធន៍តាមក្រុម | អាស៊ីត + បាស → អំបិល + ទឹក | -ធ្វើពិសោធន៍ និងសង្កេត |
| -តើអំពើខាងលើនេះអាចបញ្ជាក់ពីលក្ខណៈអាស៊ីតបានដែរឬទេ? ហេតុអ្វី? | | -អាចបញ្ជាក់ពីលក្ខណៈអាស៊ីតបានដែលបញ្ជាក់ថាអាស៊ីតប្រតិកម្មមួយបាសឱ្យផលជាអំបិលនិងទឹក ។ |
| -ចូរប្អូនសាកល្បងឱ្យនិយមន័យអាស៊ីតដោយផ្អែកលើលទ្ធផលខាងលើទាំងពីរនេះ ។ | **-និយមន័យអាស៊ីត :** ជាសារធាតុគីមីដែលក្នុងរូបមន្តវាមានធាតុអ៊ីដ្រូសែនហើយមានអំពើជាមួយបាសឱ្យផលជាអំបិល និងទឹក ។ | -អាស៊ីតជាសារធាតុគីមីដែលក្នុងរូបមន្តវាមានធាតុអ៊ីដ្រូសែន(H)ហើយមានអំពើជាមួយបាសឱ្យផលជាអំបិល និងទឹក ។ |
| -បង្ហាញសូលុយស្យុងនៃសារធាតុមួយចំនួនដូចជា ៖ ទឹកខ្មេះ ទឹកក្រូចឆ្មារ ទឹកសូដា ទឹកផេះ ទឹកសាប៊ូ និងទឹក លាងបង្គន់ ។ល។ | -អត្តសញ្ញាណកម្មសូលុយស្យុង ក្នុងជីវភាពប្រចាំថ្ងៃដោយប្រើ ក្រដាសpH និងទឹកស្ពៃក្តោបពណ៌ស្វាយ ។ | -គិត និងសាកល្បងឆ្លើយ |
| -បំផុសសំណួរ ៖ តើយើងធ្វើដូចម្តេចទើបដឹងថាសូលុយស្យុងណាខ្លះជាអាស៊ីត? -ណែនាំពីដំណើរការធ្វើអត្តសញ្ញាណកម្មដល់សិស្ស និងឱ្យសិស្សធ្វើ |  | -ធ្វើសកម្មភាពពិសោធន៍ និងកត់ត្រា + បណ្តក់សូលុយស្យុងទឹកស្ពៃក្តោបពណ៌ស្វាយ៣ ឬ៤ដំណក់ទៅក្នុងបំពង់សាកនិមួយៗ រួចកត់ត្រាពណ៌ចូលតារាង ។ |

<table>
<tr>
<td>ពិសោធន៍តាមក្រុម។<br><br>-គ្រូវពន្យល់បំផុសបន្ថែមដើម្បីឱ្យសិស្សកត់សម្គាល់ឃើញថាអាស៊ីតមានតម្លៃpH‹7 និងហៅឱ្យសិស្សកត់</td>
<td>ទឹកជេះ ទឹកសាប៊ូម្សៅ ទឹកលាងបង្គន់<br><br>* តារាងលទ្ធផល
<table>
<tr><td>ល.រ</td><td>ប្រភេទសូ.</td><td>អ.ធចង្អុលពណ៌</td><td>តម្លៃpH</td></tr>
<tr><td>១</td><td>ទឹកខ្មេះ</td><td></td><td></td></tr>
<tr><td>២</td><td>ទឹកក្រូចឆ្មារ</td><td></td><td></td></tr>
<tr><td>៣</td><td>ទឹកសូដា</td><td></td><td></td></tr>
<tr><td>៤</td><td>ទឹកជេះ</td><td></td><td></td></tr>
<tr><td>៥</td><td>ទឹកសាប៊ូ</td><td></td><td></td></tr>
<tr><td>៦</td><td>ទឹកលាងបង្គន់</td><td></td><td></td></tr>
</table>
អាចកែសម្រួលតារាង តាមអ្វីដែលមាន ឬតាមគំនិត/យោបល់របស់សិស្ស</td>
<td>+ យកក្រដាសpH ជ្រលក់ចូលក្នុងបំពង់សាកមួយៗ រួចផ្ទៀងពណ៌ និងតម្លៃpH និងកត់ត្រាចូលតារាង ។<br>-ស្តាប់ និងកត់ត្រា</td>
</tr>
<tr>
<td>-សួរសំណួរ :<br>១.តើសូលុយស្យុងខាងលើណាខ្លះជាអាស៊ីត?<br>២.តើអាស៊ីតអាចបម្រែពណ៌ទឹកស្ពៃក្តោបពណ៌ស្វាយក្លាយជាពណ៌អ្វី?<br>៣.តើអាស៊ីតមានតម្លៃpHដូចម្តេច?</td>
<td>ជំហានទី៤ (១០នាទី)<br>ពង្រឹងចំណេះដឹង<br><br>-ញែកបានពីអាស៊ីតពីសូលុយស្យុងក្នុងជីវភាពប្រចាំថ្ងៃ។<br>-ការប្រែពណ៌អង្គធាតុចង្អុលពណ៌ក្នុងសូលុយស្យុងអាស៊ីត។<br>-តម្លៃpH</td>
<td>-សរសេរចម្លើយលើក្តារឆ្នួន<br>១.ទឹកខ្មេះ ទឹកក្រូចឆ្មារ ទឹកលាងបង្គន់ និងទឹកសូដា ។<br>២.ប្រែជាពណ៌ក្រហម ឬផ្កាឈូក។<br><br>៣.អាស៊ីតមានតម្លៃpHតូចជាង7</td>
</tr>
<tr>
<td>-សរសេរសំណួរលើក្តារខៀន<br>-បណ្តាអាស៊ីតខាងក្រោមណាខ្លះជាអាស៊ីតអាចបង្កគ្រោះថ្នាក់(អាស៊ីតខ្លាំង) និងណាខ្លះជាអាស៊ី</td>
<td>ជំហានទី៥ (៣នាទី)<br>កិច្ចការផ្ទះ<br><br>-ញែកសម្គាល់អាស៊ីតខ្លាំង និងអាស៊ីតខ្សោយ</td>
<td>-អាស៊ីតគ្រោះថ្នាក់(អាស៊ីតខ្លាំង)មានដូចជា $HCl$ $HNO_3$ និង $H_2SO_4$ ។<br>-អាស៊ីតអាហារ(អាស៊ីតខ្សោយ)មាន</td>
</tr>
</table>

| | | |
|---|---|---|
| គអាហារ(អាស៊ីតខ្សោយ)៖<br>- អាស៊ីតទឹកខ្មេះ($CH_3COOH$)<br>- ទឹកក្រូចឆ្មារ ជា អាស៊ីតស៊ីទ្រិច ($C_6H_8O_7$)<br>- អាស៊ីតក្នុងទឹកលាងបង្គន់(HCl)<br>- អាស៊ីតអាគុយ($H_2SO_4$)<br>- អាស៊ីតតាក់ទ្រិច ($C_4H_6O_6$)<br>- អាស៊ីតនីទ្រិច($HNO_3$) | | ដូចជា $CH_3COOH$ $C_6H_8O_7$ និង $C_4H_6O_6$ ។<br>(ពីព្រោះជាអាស៊ីតសរីរាង្គ (អង់គ្លេស៖ organic) ដែលមានកាបូន (C)) |

រូបគំនូរតុក្កតាគំនិតទី៧៦ (VVOB) "ក្រូចមានជាតិអាស៊ីត"



# ឯកសារយោង

សៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា៖

- គណិតវិទ្យា ថ្នាក់ទី៧ (បោះពុម្ព ឆ្នាំ២០១៥)
- គណិតវិទ្យា ថ្នាក់ទី៨ (បោះពុម្ព ឆ្នាំ២០១៣)
- គណិតវិទ្យា ថ្នាក់ទី៩ (បោះពុម្ព ឆ្នាំ២០១២)
- វិទ្យាសាស្ត្រ ថ្នាក់ទី៧ (បោះពុម្ព ឆ្នាំ២០១២)
- វិទ្យាសាស្ត្រ ថ្នាក់ទី៨ (បោះពុម្ព ឆ្នាំ២០១២)
- វិទ្យាសាស្ត្រ ថ្នាក់ទី៩ (បោះពុម្ព ឆ្នាំ២០១២)

ឯកសារណែនាំសម្រាប់គ្រូបង្រៀនរបស់គម្រោង STEPSAM3 (អង្គការ JICA)

- គណិតវិទ្យាថ្នាក់ទី៧ ដល់ទី៩ (បោះពុម្ព ឆ្នាំ២០១៦)
- រូបគណិតវិទ្យាថ្នាក់ទី៧ ដល់ទី៩ (បោះពុម្ព ឆ្នាំ២០១៦)
- គីមីវិទ្យាថ្នាក់ទី៧ ដល់ទី៩ (បោះពុម្ព ឆ្នាំ២០១៦)
- ជីវវិទ្យាថ្នាក់ទី៧ ដល់ទី៩ (បោះពុម្ព ឆ្នាំ២០១៦)
- ផែនដីវិទ្យាថ្នាក់ទី៧ ដល់ទី៩ (បោះពុម្ព ឆ្នាំ២០១៦)

ឯកសារណែនាំគ្រូបង្រៀនរបស់គម្រោង SEAL (អង្គការ VVOB)

- VVOB SEAL ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី១ (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី២ (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ផ្នែកទី៣ (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍គីមីវិទ្យា (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍ជីវវិទ្យា (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍ផែនដី និងបរិស្ថានវិទ្យា (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍រូបវិទ្យា ភាគ 1 (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍រូបវិទ្យា ភាគ 2 (បោះពុម្ព ឆ្នាំ២០១២)
- VVOB SEAL ពិសោធន៍វិទ្យាសាស្ត្រ (បោះពុម្ព ឆ្នាំ២០១២)

ឯកសារណែនាំគ្រូបង្រៀនរបស់អង្គការ VSO

- VSO សៀវភៅគាំទ្រការពិសោធន៍សម្រាប់គ្រូមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី៧ ៨ ៩ (បោះពុម្ព ឆ្នាំ២០១៦)
- VSO ឯកសារណែនាំឧបករណ៍ ស្តីពី ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រក្នុងអគារធនធាន កម្រិតមធ្យមសិក្សា(បោះពុម្ព ឆ្នាំ ២០១៤)

ឯកសារពីគម្រោង "ការបណ្តុះបណ្តាលគ្រូ អប់រំជាមូលដ្ឋាន " (BETT) (ក្រសួង អប់រំ យុវជន និងកីឡា ជាមួយអង្គការ VVOB) ឯកសារណែនាំគ្រូឧទ្ទេស គ្រូបង្រៀន និងឯកសារសកម្មភាពសិស្សតាមកម្មវិធីមាន ៖

- ផ្នែកទី១ អំពីចំនួន (បោះពុម្ព ឆ្នាំ២០០៨)
- ផ្នែកទី២ ការគណនា (បោះពុម្ព ឆ្នាំ២០០៨)
- ផ្នែកទី៣ ពីជគណិត (បោះពុម្ព ឆ្នាំ២០០៨)
- ផ្នែកទី៤ ស្ថិតិ (បោះពុម្ព ឆ្នាំ២០០៨)
- ផ្នែកទី៥ ធរណីមាត្រ (បោះពុម្ព ឆ្នាំ២០០៨)
- ផ្នែកទី៦ រង្វាស់រង្វាល់ (បោះពុម្ព ឆ្នាំ២០០៨)